សារព័ត៌មាន ខ្មែរផុស ស.រ.អា
KhmerPost USA
E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 1 (267) 253-3947


# គណបក្សសង្គ្រោះជាតិសង្ខើញរកទីបញ្ចប់ _គណបក្សប្រជាជនទ្រាំលែងបាន

ដោយ : ពិន សំខុន

បាតុកម្ម: នាចុងឆ្នាំ២០១៣នេះបាតុកម្ម អហឹង្សារបស់គណបក្សសង្គ្រោះជាតិ បានផុសផុល

តទៅទំព័រទី ១១





The Haskell Family

ការិយាល័យច្បាប់លូវីស ហាស់ស្កែល
យើងខ្ញុំទទួលធ្វើតាក់ និងប្រឹក្សា
Law Office Of Louis S. Haskell
We Do Tax Preparation & Planning!
• Individuals • Business • Corporations
• បុគ្គលឯកជន • ជំនួញក្រុមហ៊ុន
• សារជីវកម្មក្រុមហ៊ុន
ការិយាល័យយើងខ្ញុំបើកបម្រើការដល់យប់ និងចុងសប្តាហ៍ក្នុងរដូវធ្វើតាក់




សូមទាក់ទង 978-459-8359
ឬមកអាស័យដ្ឋាន 16 Pine Street #2, Lowell, MA

I DO TAXES
ខ្ញុំទទួលធ្វើតាក់ជូនលោកអ្នក
មានបទពិសោធន៍២៥ឆ្នាំ
យើងបម្រើធ្វើតាក់សម្រាប់លោកអ្នក
ការិយាល័យយើងខ្ញុំបើកពេលយប់ និង
ចុងសប្តាហ៍(រដូវធ្វើតាក់)



Law Office of Thomas Stylianos
287 Appleton Street Lowell MA 01852
(978) 459-5000

Create Success

Over the years, Enterprise Bank has learned the importance of remaining a genuine community bank by hiring people of diverse cultures, making decisions on the local level, providing personalized, responsive service in your native language, and offering a wide range of financial possibilities. Bopha and Sue would be happy to speak to you in Khmer on how Enterprise Bank can assist you with your financial needs.



Bopha Malone
Branch Relationship Manager, AVP
Lowell Connector Branch
430 Gorham Street
Lowell, MA 01852
(978) 656-5561



Sue Suon
Branch Service Specialist
Main Office Lowell Branch
222 Merrimack Street
Lowell, MA 01852
(978) 656-5679

Call Bopha Malone or Sue Suon today and let them help you Create Success!

Enterprise Bank
CREATE SUCCESS
EnterpriseBanking.com

# KhmerPost USA

The Cambodian-American Biweekly Newspaper

សារព័ត៌មានខ្មែរ-អាមេរិក ចេញពីរសប្តាហ៍ម្តង

a free local newspaper reaching over 20,000 Cambodian readers in the Greater Lowell area every two weeks .

ផ្តល់ជូនកាសែតឥតគិតថ្លៃដល់អ្នកអានខ្មែរច្រើនជាង២០០០០នាក់នៅតំបន់ឡូវែលរាល់ពីសប្តាហ៍ម្តង

Soben Pin, Managing Partner អ្នកគ្រប់គ្រង សុបិន្ត ពិន

978.677.7163 (Office) 978. 656.8141 (Mobile)

សូមកក់ពាណិជ្ជកម្មអ្នកជាមួយយើងខ្ញុំ ហើយទទួលបានការបញ្ចុះតម្លៃ២០%

Reserve Your 2014 Ads with us today and receive up to 20% OFF!

(Please mention this coupon ad: Winter2013)

## Sample of our affordable pricing បញ្ជីតម្លៃពាណិជ្ជកម្មក្នុងតម្លៃសមរម្យ

| ទំហំទំព័រ Page Size | ប្រវែង Length x Width | 1ខែ 1 month | 3 ខែ 3 months 10%OFF | 6 ខែ 6 months 15%OFF | 12 ខែ 12 months 20%OFF |
|---|---|---|---|---|---|
| 1/2 page color | (6.5"x10") | $484 | $440/m | $411/m | $387/m |
| 1/4 page color | (6.5"x5") | $264 | $240/m | $224/m | $211/m |
| 1/4 Classify Ad | (6.5"x5") | $160 | | | |
| 1/8 Classify ad | (3.25"x5") | $100 | | | |
| Business Card | | $50 | | | |

## Our 2014 Publishing Dates កាលវិភាគបោះពុម្ព

| | |
|---|---|
| January 10th & 24th | July 11th & 25th |
| February 7th & 21st | August 8th & 22nd |
| March 7th & 21st | September 5th & 19th |
| April 4th & 25th | October 10th & 24th |
| May 9th & 23rd | November 7th & 21st |
| June 6th & 20th | December 5th & 19th |

*all ad materials are due one week prior to publishing date.

រាល់គំរូពាណិជ្ជកម្មត្រូវបញ្ជូន1សប្តាហ៍មុនចូលរោងពុម្ព




## Call or Visit our Sales Office

45 Merrimack Street. Suite 218A. Lowell, MA 01852

Tel: 978.677.7163. Cell: 978. 656.8141 Fax: 978.677.7092

Email: sobenpin@khmerpost.us or KhmerPostUSA@gmail.com

www.khmerpost.us | www.facebook.com/KhmerPostUSA



# ដំណើរតាមជើងសមុទ្រ "អាត់ឡង់ទិក"

**តពីលេខមុន**

យើងបានឆ្លងរាត្រីទី១ នៅលើមហាសាគរ "អាត់ឡងទិក" នៅលើនាវាទេសចរណ៍ "ន័រវេសុី យានគ្រួស៍ឡាញ" (Norvegian Cruise Line) ពីញូយ៉កសំដៅទៅហ្លូរីដាយ៉ាងអស់កម្លាំងទន់ខ្លួន ដោយធ្វើដំណើរឆ្ងាយទម្រាំបានដល់កន្លែងសម្រាកកាយ ទម្រាំដល់ពេលចប់កម្មវិធីបង្ហើនយ៉ាងរន្ថើនសម្រាប់ទទួលភ្ញៀវ ហើយក៏លុងលក់ដូចសម្លប់ទាំងបីនាក់ទៅ។ ស្អែកឡើងនាវានៅតែរំកិលទៅមុខដូចនាគសមុទ្រ រុំព័ទ្ធដោយទឹកពណ៌ខៀវ ស្រងាត់តែថ្លាឆ្វង់ វលកតិចក្នុងធាតុអាកាសក៏កាន់តែក្តៅឡើង ពីព្រោះយើង ទើបនឹងចុះមកខាងត្បូង ស្មើនឹង "វៀសុីញ៉ា" នៅឡើយទាល់តែឆ្លង១យប់ទៀត ទើបដល់"ហ្លរីដា"។

ស្អែកឡើងយើងភ្ញាក់រៀបចំខ្លួនទៅស្រស់ស្រូបពេលព្រឹកនៅជាន់ទី១៥ ម៉ោង ១០ព្រឹក នោះមានមនុស្សម្នាណែនណាន់តាន់តាប់នៅភោជនីយដ្ឋានដ៏ធំវែងល្វឹងល្វើយនោះ យើងមានអារម្មណ៍មួរម៉ៅដោយដើររក២ជុំបណ្តោយជាង១០០មទទឹង៥០ម តុកៅអីរាប់ពាន់ហើយ នៅតែមិនមានតុទំនេរសម្រាប់យើងទីបញ្ចប់យើងរកបានកន្លែងអង្គុយនាចុងនាវាហើយ ក៏ល្ហួងចិត្តទៅវិញពេលមើលឃើញទេសភាពត្រកាលនៃសមុទ្រពណ៌ខៀវខ្ចី ថ្ងៃចាំងស្រឡះមុខធាតុអាកាសឡើងលើស១៥អង្សាC។ ខ្ញុំចាប់អារម្មណ៍ លើនាវាដែលទទួលភ្ញៀវបានច្រើនម្លឹង១ ហើយនៅតែមិនគ្រប់គ្រាន់ តើប្រើប្រាស់វត្ថុធាតុដើមច្រើនប៉ុណ្ណាទើបគ្រប់គ្រាន់បំពេញចិត្តភ្ញៀវបាន ? មែនមានៈអ្នកបំរើឆ្វេងស្តាំស្លៀកឯកសណ្ឋានស្អាតភ្លឹងរយនាក់បំរើមហូបរយពាន់ស្តុកប្រកបដោយគុណភាពប្រណិតគ្មានភ្លេចត្រង់ណា ចំណែកឯភ្ញៀវវិញ មានខ្លះមានសំលៀកបំពាក់សេរី រហូតដល់ខោ អាវខ្លី ឬស្លីពកំប៉ុតឡិត ដោយសារនៅមិនឆ្ងាយពីអាងហែលទឹក ក៏ចុលមកស្រស់ស្រូបដែរ ។ **តទៅទំព័រទី ២១**








# ការិយាល័យច្បាប់ ហ្វ្រង់សុីស្កូ ជេ.រ៉ូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ សុីស្កូ ជេ.រ៉ូសា



Bunna Andrew Taing , Juris Doctor
លោក ប៊ុណ្ណា អែនឌ្រូ តាំង

Law Office of:
FRANCISCO J. ROSA
ATTORNEY AT LAW

SERVICES
- Personal Injury/Auto Accidents
- Bankruptcy
- Immigration
- Social Security Disability
- Landlord/Tenant
- Consumer Protection
- Real Estate Closings/Disputes
- Divorces
- Child Support & Custody
- Other legal needs

តំណាងក្តីដូចខាងក្រោម
- របួសរូបរាងកាយ/គ្រោះថ្នាក់រថយន្ត
- ក្ស័យធន
- អន្តោប្រវេសន៍
- អសមត្ថភាពផ្នែកសុវត្ថិភាពសង្គម
- ម្ចាស់ផ្ទះ / អ្នកជួល
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ
- អាហារកិច្ច និងអាណាព្យាបាលកិច្ច
- សេចក្តីត្រូវការផ្នែកច្បាប់ផ្សេងទៀត

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com

# ម៉ៅ លួស៊ី ជ័យលាភី បវរកញ្ញាខ្មែរប្រចាំប្រទេសបារាំង ឆ្នាំ២០១៤

**ដោយ : សុខា**

**ប៊ូស៊ីសាំងចច, ប្រទេសបារាំង:** នាថ្ងៃទី២២ ខែធ្នូ ឆ្នាំ ២០១៣ ឯប្រទេសបារាំង នៅប៊ូស៊ីសាំងចច ជាតំបន់ផ្នែកខាងកើតឈៀងខាងត្បូងនៃទីក្រុងប៉ារីសដែលមានខ្មែររស់នៅច្រើន មានការរៀបចំកម្មវិធីប្រឡងជ្រើសរើសបវរកញ្ញាខ្មែរប្រចាំប្រទេសបារាំងសម្រាប់ឆ្នាំ២០១៤។

ជ័យលាភីគឺបានទៅលើកញ្ញា ម៉ៅ លួស៊ី ទទួលបានសម្លេងគាំទ្រ ៤៥០ សម្លេង។ គួរបញ្ជាក់ផងដែរ ការប្រឡងខាងលើនេះមានការចូលរួមដោយយុវតីខ្មែរបារាំងចំនួន១៩នាក់។



កញ្ញា ម៉ៅ លួស៊ី



យុវតីខ្មែរដ៏ស្រស់ស្អាត១៩រូប ចូលប្រកួតសម្រស់

ការប្រកួតជ្រើសរើសបានធ្វើការប្រកាសលទ្ធផលរាប់ថយក្រោយពីលេខ៥ ឡើងមកលេខមួយក្នុងនោះ លេខ៥បានទៅលើកញ្ញា សិទ្ធ សេរេណា ទទួលសម្លេងគាំទ្រ៣៣៦ លេខ៤ សែន ទេពបូរ៉ា ៣៨៣ លេខ៣ ឈឿន ចរិយា ៣៩៩ លេខ២ យ៉ាន ស៊ីនឌី ៤១៤ និង លេខ១ ម៉ៅ លួស៊ី ទទួលសម្លេងគាំទ្រ៤៥០។

ការដាក់ពិន្ទុជ្រើសរើសបវរកញ្ញាខ្មែរប្រចាំប្រទេសបារាំងក៏មានវគ្គសំណួរចម្លើយមិនខុសពីការប្រឡងជ្រើសរើសបវរកញ្ញាពិភពលោកឡើយ ដោយឡែកតែវិញ្ញាសារប្រមូលផ្តុំដោយសំណួរទាក់ទងនឹងប្រវត្តិសាស្រ្ត ប្រពៃណី វប្បធម៌ និងទំនៀមទំលាប់ខ្មែរ ដូចជា

**បវរកញ្ញាស្លាកលេខ១:** តើប្រភេទក្រណាត់ត្បាញនៅប្រទេសខ្មែរមានអ្វីខ្លះ?

**បវរកញ្ញាស្លាកលេខ២:** បើក្លាយជាបវរកញ្ញាខ្មែរប្រទេសបារាំងចង់សម្រេចបំណងប្រាថ្នាអ្វីខ្លះដែរ?

**បវរកញ្ញាស្លាកលេខ៣ :** សូមរៀបរាប់ប្រាសាទបុរាណចំនួនប្រាំដែលស្ថិតក្នុងខេត្តនៃប្រទេសកម្ពុជា។

**បវរកញ្ញាស្លាកលេខ៤:** តើតម្រូវឱ្យមានលក្ខណ:សម្បត្តិអ្វីខ្លះដើម្បីឱ្យទទួលបាននាមជាបវរកញ្ញាខ្មែរប្រចាំប្រទេសបារាំង?

**បវរកញ្ញាស្លាកលេខ៥:** តើភ្នំអ្វីដែលមានកម្ពស់ខ្ពស់ជាងគេនៅប្រទេសកម្ពុជា?

**បវរកញ្ញាស្លាកលេខ៦ កញ្ញា លីមកណ្ណិកា :** តើមានទន្លេអ្វីខ្លះហូរកាត់ប្រទេសកម្ពុជា?

**បវរកញ្ញាស្លាកលេខ៧ កញ្ញា អេង ស្រីឡុង :** តើប្រទេសកម្ពុជាមានប៉ុន្មានខេត្តក្រុង?

**បវរកញ្ញាស្លាកលេខ ៨ កញ្ញា លីនដា :** តើមានអង្ករប៉ុន្មានប្រភេទនៅប្រទេសកម្ពុជា? ហើយមានឈ្មោះអ្វីខ្លះ?

**បវរកញ្ញាស្លាកលេខ៩ កញ្ញា ធីម ចិន្តា :** តើស្តេចអង្គណាដែលបានចូលរួមកសាងប្រាសាទអង្គរវត្ត? ហើយក្នុងសម័យណា?

**បវរកញ្ញាស្លាលលេខ ១០ កញ្ញា ជូលី :**

តទៅទំព័រទី ០៦

មជ្ឈមណ្ឌលបម្រើសេវាដល់មនុស្សចាស់
សម្រាប់សហគមន៍អាស៊ាន
Penn Asian Senior Services
PASSi







ដើម្បីបំពេញនូវសេចក្តីត្រូវការផ្នែកសេវាសុខភាពសម្រាប់មនុស្សចាស់នៃសហគមន៍អាស៊ាន ប៉ាស៊ី(PASSI) បានទិញ នូវអគារបន្ថែមសម្រាប់ធ្វើការក្នុងតំបន់ហ្វីឡាដែលហ្វៀ ។

មជ្ឈមណ្ឌលបម្រើសេវាដល់មនុស្សចាស់សម្រាប់សហគមន៍អាស៊ានបានបើកការិយាល័យបន្ថែមនៅអាស័យដ្ឋានថ្មីផ្លូវ 6926 Old York Rd, Philadelphia PA 19126 ។ អគារនេះមានទំហំ 29,300Sqft និងបំពាក់ដោយបរិក្ខាបម្រើសេវាថែទាំមនុស្សចាស់ចាប់ផ្តើមពីខែមីនាខាងមុខនេះតទៅ។ គ្រឿងបរិក្ខាដែលបំពាក់ក្នុងអគារថ្មីនេះ នឹងផ្តល់នូវផាសុកភាព និងសោភ័ណភាពក្នុងការរស់នៅដោយឯករាជ្យរបស់មនុស្សចាស់ក្នុងសហគមន៍អាស៊ានឱ្យបានកាន់តែប្រសើរឡើង ។

ព័ត៌មានបន្ថែមសូមហៅគន្ធា : 215-572-1234
ឬចូលគេហទំព័រ : www.passi.us



6926 Old York Rd, Philadelphia PA 19126



CONWAY
INSURANCE AGENCY

រយៈពេល២៥ឆ្នាំ ភ្នាក់ងារធានារ៉ាប់រងខុនវ៉េយបានបម្រើសហគមន៍ដោយធានារ៉ាប់រងគ្រប់មុខប្រកបដោយគុណភាពនៅតំបន់ញូអ៊ីងឡែន ។
យើងខ្ញុំជាភ្នាក់ងារបំពេញសេវាគ្រប់មុខដូចខាងក្រោម :

ការធានារ៉ាប់រងគ្រួសារ
- រថយន្ត
- ផ្ទះ
- ផ្ទះល្វែង
- គ្រឿងអលង្ការ
- វត្ថុសិល្បៈ
- វត្ថុបុរាណ

ការធានារ៉ាប់រងជំនួញ
- អចលនវត្ថុ
- សុវត្ថិភាពជំនួញ (Liability)
- សុវត្ថិភាពជំនាញ (Professional Liability)
- រីកខីខម (Worker's Compensation)
- បនដស៍ (Bonds)
- អ្នកមើលថែឡាន និងការ៉ាស់ឡាន
- ធានារ៉ាប់រងពិការភាព និងជីវិត
- កម្មវិធីពិសេសផ្សេងៗទៀត

CONWAY INSURANCE AGENCY
77 E. Merrimack Street. Lowell, MA 01852
Tel: 978-454-5054|Fax 978-453-2480
www.conwayinsurance.com
សូមទាក់ទងមក : ហ្វីលីប មុត, អ្នកគ្រប់គ្រង

# វាចារលោក វាស្នា នួន នាឱកាសដាច់ឆ្នាំ ២០១៣

"តពីលេខមុន"

**បទសម្ភាសន៍ដោយ : ពិន សំខុន**

**ខ្មែរផុស :** យើងមិនដែលឮលោកបញ្ចេញយោបល់ក្នុងតួនាទីជាសមាជិកក្រុមប្រឹក្សាក្រុងឡូវែល អំពីរឿងអាជ្ញាប័ណ្ណវត្តខ្មែរឡូវែលរបស់ព្រះតេជគុណ សៅ ឃន នៅឡើយ តើវត្តនោះអាចសង់បានឬក៏មិនបាន?

**វាស្នា នួនៈ** រឿងហ្នឹងឥតទាក់ទងនឹងក្រុមប្រឹក្សាក្រុងទេ តែក្រុមប្រឹក្សាអាចមានសម្លេងក្នុងហ្នឹង កាលពីមុនរឿងអាស្រូវនៅ "វត្តខ្មែរថ្មី" ហ្នឹង សមាគមតំបន់គេហ្នឹងជំទាស់ដាច់ខាតថាមិនឱ្យសង់វត្តបានទេ គេថា "ជាដំបន់ទឹកលិច" តែតំបន់ទាំងអស់មិនមែនទឹកលិចតែទាំងអស់នោះទេ ម្យ៉ាងទៀតនោះគេក៏មានវិធីសាស្ត្រសំរាប់សង់នៅកន្លែងទឹកលិចដែរ ដូចនៅ "អាល់ក្លីក" ដែលនៅក្បែរហ្នឹងកន្លែងដីធំប៉ុនណាណីម៉េចក៏សង់បាន?

**ខ្មែរផុសៈ** តើដោយសារតែ "ប្លង់" ដែលបង្ហាញពីវិហារធំ មានកំពូលប្រសាទដូចអង្គរវត្តនោះឬ ដែលគេមិនឱ្យអាជ្ញាប័ណ្ណសម្រាប់សង់ (រូប១)

**វាស្នា នួន :** បាទ ១ តែមិនមែនរឿងសង់ហ្នឹងប៉ុន្មានទេ តែពេលលោកទិញដីមកហើយហ្នឹងលោកឥតដឹង។

**២,**ច្បាប់ទម្លាប់ ទៅកាប់ឆ្ការព្រៃដែលគេថែរក្សារបរិដ្ឋាន ទៅដាក់ "ត្រេល័រ" ឥតសុំច្បាប់ ដោយសារយើងឥតដឹងមុនមែន ហើយទៅធ្វើមុនរួចមកសុំច្បាប់ ក៏ធ្វើឱ្យគេមានប្រតិកម្មបំពាននឹងច្បាប់ក្រុមប្រឹក្សាក្រុងហ្នឹងខ្លាចសម្លេងអ្នកភូមិប្រឆាំង... តែអ្នកភូមិជុំវិញហ្នឹង ពុំមែនជាសម្លេងអ្នកភូមិនៃតំបន់ហ្នឹងទាំងមូលនោះទេ... នៅក្រុមប្រឹក្សាក្រុងពេលនោះមាន "រ៉ិតនី អាល់" មាន "ជោរបានឌុការ" មិនបែនត្រចៀកសងណា តែប្រឆាំងនឹងមតិភាគច្រើនមិនបាន ដល់អីចឹងទៅរឿងហ្នឹងក៏ឡើងទៅ "ជៀនសរេវ៉ាតៀន" គេបោះឆ្នោតឱ្យទេតើ ! តែអ្នកភូមិប្តឹងបន្តរ ក៏ឡើងទៅ "ភៅគីក្រុមអភិរក្សតំបន់" បន្តរទៅទៀតដែលនៅទីនោះគេមិនជុំទាស់ទេ តែចេញបញ្ជាលក្ខខណ្ឌថា "ដើម្បីឱ្យសង់ទៅកើតត្រូវធ្វើយ៉ាងនេះយ៉ាងនោះទៅ១ ពេលនោះមុនមានកើតរឿងអាស្រូវនៅក្នុងវត្ត ខ្ញុំក៏ពុំបានតាមដាន...ដូច្នេះសួរថាតើសង់វត្តនោះ បានឬមិនបាន ? មិនមែនមិនបានទេ តែអ្នកដែលមានជំនឿលើវត្តនោះត្រូវធ្វើទៅតាមលក្ខខណ្ឌទាំងនោះឱ្យបានត្រូវមានលុយជួលមេធាវី ត្រូវមានលុយធ្វើតាមបទបញ្ជាក្រសួង ទើបបន្តរទៅមុខទៀតបាន។

**ខ្មែរផុស :** ក្នុងឆ្នាំនេះ មានរឿងវត្តមួយទៀតដែរ គឺវត្តត្រៃរតនារាម ដែលមានប្រជាពលរដ្ឋនៅឡូវែលបានបះបោរ- បន្ទាប់ពីតុលាការក្រុងសម្រេចឱយរៀបរយវត្តនោះ ឱ្យទៅជាមួយវិញ តែមកទល់ថ្ងៃនេះវត្តនៅតែជាវត្តលើ-វត្តក្រោមដដែល តើសាលាក្រុងមានឥទ្ធិពលអ្វីទេទៅលើវត្តខ្មែរមួយនេះ។

**វាស្នា នួនៈ** ក្រុងមិនដែលមានឥទ្ធិពលអ្វីទៅលើវត្តនោះទេ ពីព្រោះវត្តត្រៃរតនារាមមិនមែននៅឡូវែលទេ។

**ខ្មែរផុសៈ** ចុះក្រែងពេលប្តឹងប្តល់គ្នា គេប្តឹងនៅឡូវែលទេតើ ?

**៣,វាស្នា នួនៈ** បាទវត្តនោះនៅក្រៅឡូវែលមែនតែនៅ **តទៅទំព័រទី ២៦**


វាស្នា នួន





## តមកនំព័រទី ៤ ម៉ៅ លូស៊ី ជ័យលាភី បវរកញ្ញាខ្មែរ...

ចំពោះកញ្ញាតើតម្រូវឱ្យមានគុណសម្បត្តិអ្វីខ្លះដើម្បីឱ្យក្លាយជាបវរកញ្ញាខ្មែរ?

**បវរកញ្ញាស្លាកលេខ ១១ កញ្ញា ស៊ុរិយានី :** សូមរៀបរាប់ស្តីពីប្រវត្តិខ្លះៗស្តីពីក្រុងភ្នំពេញ?

**បវរកញ្ញាស្លាកលេខ ១២ :** ក្នុងកម្មវិធីអាពាហ៍ពិពាហ៍ខ្មែរពេលសំពះផ្ទឹម?

**បវរកញ្ញាស្លាកលេខ ១៣ កញ្ញា សុមេត្រី :** សំណួរស្តីអំពីពិធីបុណ្យសាសនា?

**បវរកញ្ញាស្លាកលេខ ១៤ កញ្ញា ស៊ានឌី :** តើខែណាដែលជាខែចូលឆ្នាំខ្មែរ?

**បវរកញ្ញាស្លាកលេខ ១៥ កញ្ញា ជូលី :** តើហេតុអ្វីបានជាគេជ្រើសរើសខែវិច្ឆិកាសម្រាប់ប្រារព្ធពិធីបុណ្យអុំទូករយៈពេលបីថ្ងៃ?

**បវរកញ្ញាស្លាកលេខ ១៦ កញ្ញា ស៊ីនឌី :** តើបុគ្គលិកលក្ខណៈសម្បត្តិអ្វីខ្លះដែលកញ្ញាផ្តោតជាភាពខ្លាំងនៃបវរកញ្ញាខ្មែរ?

**បវរកញ្ញា ស្លាកលេខ ១៧ កញ្ញា ឌី បូរ៉ា :** សូមពិពណ៌នាអំពីទំនៀមទំលាប់នៃការប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ?

**បវរកញ្ញាស្លាកលេខ ១៨ កញ្ញា ចរិយា :** សូមរៀបរាប់ស្តីពីរបាំក្ងោក?

**បវរកញ្ញាស្លាកលេខ ១៩ កញ្ញា ម៉ៅ លូស៊ី :** សូមរៀបរាប់ថ្ងៃខួបកំណើតទាំងបីថ្ងៃនៃទំនៀមទម្លាប់ដែលមានក្នុងប្រទេសកម្ពុជា?



កម្មវិធីខាងលើរៀបចំដោយសមាគមគណៈកម្មការជ្រើសរើសបវរកញ្ញាខ្មែរប្រចាំប្រទេសបារាំង ហើយមានការចូលរួមយ៉ាងច្រើនកុះករពីគណៈធិបតីជាតិ និងអន្តរជាតិ និងភ្ញៀវកិត្តិយសជាច្រើនដែលញ៉ាំងកម្មវិធីខាងលើប្រព្រឹត្តទៅដោយជោគជ័យ ។

កញ្ញា ម៉ៅ លូស៊ី ដែលទទួលបាននាមជាកញ្ញាឯកខ្មែរប្រចាំប្រទេសបារាំងនឹងក្លាយជាស្រ្តីតំណាងសហគមន៍ខ្មែរពេលនាងមានវត្តមាននៅកម្មវិធី និងទីកន្លែងនានា ៕




# ក្រុងសៀមរាបទទួលបាន ចំណាត់ថ្នាក់លំដាប់លេខ២៣

## ក្នុងចំណោម២៥ទិសដៅទេសចរណ៍ក្នុងពិភពលោកសម្រាប់ឆ្នាំ២០១៣

**ដោយ : សុខា**

ទ្រីបអែតវៃសឺរ (Trip Advisor) ជាគេហទំព័រដែលមានអត្ថប្រយោជន៍ដល់ប្រជាជន និងទេសចរដែលចង់ឱ្យដំណើរកំសាន្តរបស់ខ្លួនបានដល់ភាពរីករាយ និងឆ្លាតវៃ ។

ថ្មីៗនេះ គេហទំព័រទ្រីបអែតវៃសឺរបានបង្ហោះព័ត៌មានតាមអ៊ីនធឺណិតពីទីតាំងតំបន់ទេសចរណ៍ល្បីល្បាញទាំង២៥ក្នុងពិភពលោក។ បើគិតពីវិសាលភាពនៃពិភពលោកដែលមានជាង២00ប្រទេស ហើយក្នុងប្រទេសនីមួយៗមានតំបន់ទេស-ចរណ៍ច្រើនសន្ធឹកសន្ធាប់ក្នុងចំនួនស្មើរគណនាមិនបានខេត្តសៀមរាបនៃព្រះរាជាណាចក្រកម្ពុជាទទួលបានចំណាត់ថ្នាក់លេខ២៣ក្នុងពិភពលោកជាតំបន់ដែលទេសចរក្នុងពិភពលោកពេញចិត្ត ។ នេះចាត់ទុកជាអំណរ និងមោទកភាពធំធេងដែលខ្មែរបានទទួល ។ ខេត្តសៀមរាបមានព្រំប្រទល់ជាប់នឹងខេត្តបាត់ដំបង បន្ទាយមានជ័យ ឧត្តរមានជ័យ ព្រះវិហារ កំពង់ធំ និងបឹងទន្លេ សាប ។

ក្រុងសៀមរាបសម្បូរហូរហៀដោយមរតកប្រវត្តិសាស្ត្រ ប្រាសាទបុរាណ ព្រៃព្រឹក្សា សត្វច្រើនប្រភេទ ភ្នំគូលែន និងជាទីទេសចរណ៍ទទួលស្វាគមន៍ បដិសណ្ឋារកិច្ចជាលក្ខណជាតិ និងអន្តរជាតិ ដោយមានការផ្តល់នូវសេវាសណ្ឋារគារគ្រប់លំដាប់ភាតរភាព និងភាពរួសរាយរាក់ទាក់ភ្ជាប់ស្នាមញញឹមស្រស់ស្រាយនៃប្រជាជនខ្មែរ ។



ទីក្រុងសៀមរាប ព្រះរាជាណាចក្រកម្ពុជាលេខ២៣



ទីក្រុងប៉ារីស ប្រទេសបារាំងលេខ១



ទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក លេខ២

គួរបញ្ជាក់ពីតំបន់ទេសចរណ៍ក្នុងពិភពលោកទាំង២៥សម្រាប់ឆ្នាំ២០១៣រួមមាន ទី១ ទីក្រុងប៉ារីស ប្រទេសបារាំង ទី២ ទីក្រុងឡុនដុន ប្រទេសអង់គ្លេស ទី៣ ទីក្រុងញូវយ៉កនៃរដ្ឋញូវយ៉កសហរដ្ឋអាមេរិក ទី៤ ទីក្រុងរ៉ូមប្រទេសអ៊ីតាលី ទី៥ ទីក្រុងប៉ាសេឡូណាប្រទេសអេស្ប៉ាញ ទី៦ទីក្រុងវេនីស ប្រទេសអ៊ីតាលី ទី៧ទីក្រុងសាន់ហ្វ្រាន់ ស៊ីស្កូនៃរដ្ឋកាលីហ្វញ៉ានៃសហរដ្ឋអាមេរិក ទី៨ទីក្រុង ហ្លរ៉ែន ប្រទេសអ៊ីតាលី ទី៩ទីក្រុងប្រាក់សាធារណរដ្ឋ ឆិក ទី១០ ទីក្រុងស៊ីដនីនៃប្រទេសអូស្ត្រាលីទី១១ ទីក្រុងប៉ែកឡាំងប្រទេសអាល្លឺម៉ង់ ទី១២ទីក្រុង អ៊ីស្តានប៊ុលប្រទេសតួរគី ទី១៣ ទីក្រុងបាងកកប្រទេសថៃ ទី១៤ ទីក្រុងជីកាហ្គូរដ្ឋអ៊ីលីណយ សហរដ្ឋអាមេរិក ទី១៥ទីក្រុងតូក្យូ ប្រទេសជប៉ុន ទី១៦ ទីក្រុងខេបថោននៃប្រទេសអាហ្វ្រិកខាងត្បូង ទី១៧ ទីក្រុងរីយ៉ូ ដឺចេនីរ៉ូ ប្រទេសប្រេស៊ីល ទី១៨ទីក្រុងប៊ូណូអ៊ែរ ប្រទេសអាចិនទីណា ទី១៩ ទីក្រុងម៉ារ៉ាកេ ប្រទេសម៉ូរ៉ូកូ ទី២០ទីក្រុងសេន ភីតថសបឺក ប្រទេសរ៉ូស៊ី ទី២១ ទីក្រុងប៉េកាំងប្រទេសចិន ទី២២ទីក្រុងសៀងហៃ ប្រទេសចិន ទី២៣ ទីក្រុងសៀមរាបប្រទេសកម្ពុជា ទី២៤ ទីក្រុងឆៀងម៉ៃប្រទេសថៃ ទី២៥ ទីក្រុងគ្វីនស៏ថោន ប្រទេសញូហ្សេឡែន ៕



ទីក្រុងឡុងដុន ប្រទេសអង់គ្លេស លេខ៣






DNA Testing
ពិនិត្យ ឌី_អិន_អេ
IMMIGRATION & LEGAL PATERNITY TESTING
978 703 0775

ការិយាល័យភស្តុតាងពិនិត្យ ឌី_អិន_អេ
GENETIC DNA TESTING
AABB Accredited Results
តម្លៃពិសេសសម្រាប់ខែធ្នូ -សូមហៅទូរស័ព្ទ ដើម្បីបានព័ត៌មានបន្ថែម
SPECIAL PRICING FOR THE MONTH OF DECEMBER – CALL FOR DETAILS



Laura Blair, President

ទទួលពិនិត្យ
- ពិនិត្យឌី.អិន.អេ ដើម្បីធ្វើអន្តោប្រវេសន៍ ដូចជាដើម្បីបាន I-BO ការចូលសញ្ជាតិលិខិតឆ្លងដែនអាមេរិក
- ពិនិត្យ ឌី.អិន.អេ ឪពុក
- ពិនិត្យ ឌី.អិន.អេ ម្តាយ
- ពិនិត្យ ឌី.អិន.អេ ឪពុកបងប្អូនបង្កើត
- ពិនិត្យ ឌី.អិន.អេ ដោយមិនផ្ទាល់
- ពិនិត្យ ឌី.អិន.អេ ស្វែងរកប្រភពកំណើត

Testing DNA SERVICES
- Immigration
- Paternity
- Maternity
- Siblingship
- Forensic
- Prenatal
- Ancestry

ផ្តល់សេវាជាសកល - ប្រមូលភស្តុតាង ឌី-អិន-អេ ទូទាំងសហរដ្ឋអាមេរិក
WORLDWIDE SERIVCE – NATIONWIDE COLLECTION SITES
Affordable prices and payment plans
MVP Testing DNA SERVICES

262 Merrimack St
Lowell, Mass 01852
Tel: 978 703 0775
Fax: 978 703 0430

30 S. Broadway
Lawrence, Mass 01843
Tel: 978 416 4111
Fax: 978 416 3400

# ទីប្រឹក្សាក្រុង និងអភិបាលក្រុងថ្មី ចូលកាន់តំណែង

## Lowell City Council and Mayor Sworn In Lynn

**អត្ថបទដោយ : ចេមស៍ អសទីស**

**ប្រែសម្រួលដោយ : សុខា**


អភិបាលក្រុងរ៉ដនីអេលៀត

ព្រឹកថ្ងៃច័ន្ទនៃដើមខែមករា ឆ្នាំ២០១៤ ទីប្រឹក្សាក្រុងឡូវែល បានធ្វើសច្ចាប្រណិធានចូលកាន់តំណែងក្លាយជាមគ្គុទេសក៍ថ្មីដឹកនាំក្រុងឡូវែលអតីតទីក្រុងឧស្សាហកម្មនៃរដ្ឋម៉ាសាឈូសេត ។ តាមប្បវេណីកាតព្វកិច្ចដំបូងក្នុងតួនាទី គឺការជ្រើសរើសអភិបាលក្រុងថ្មីសម្រាប់អាណត្តិនោះ។ ជាលទ្ធផលទីប្រឹក្សាក្រុង រ៉ដនី អេលៀត ដែលបំពេញកិច្ចការនេះជាយូរអង្វែងមក ហើយនោះត្រូវបានជ្រើសរើសជាអភិបាលក្រុង ខណៈដែលលោកទន្ទឹងរង់ចាំតំណែងនេះរយៈពេល១៦ឆ្នាំមកហើយ។

ក្រុមប្រឹក្សាមានទីប្រឹក្សាក្រុង៥រូបពីមុន ក្នុងនោះ មានរីតា មឺស៊្យ បេក្ខជនដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេនារដូវកាលបោះឆ្នោតខែវិច្ឆិកា អេលៀត, អេដវឺត ខេណេឌី, បៀល ម៉ារទីន និង ចន លាហ៊ី ដែលត្រូវបានជាប់ឆ្នោតសម្រាប់តំណែងអនុប្រធានក្រុមប្រឹក្សា ។ ទីប្រឹក្សាថ្មីថ្មោងក្នុងតួនាទីជាទីប្រឹក្សាក្រុង រួមមាន ដែននីរូគី, អតីតនាយកវិទ្យាល័យឡូវែល វីលលៀមបៀល សាម៉ារ៉ាស និង អតីតគណៈកម្មការតំបន់ ខរី បីលែនជឺ ។ អតីតអភិបាលក្រុង និងជាអតីតទីប្រឹក្សាក្រុង ជីម មីលីណាហ្សូ នឹងត្រលប់មកកាន់ក្រុមប្រឹក្សាវិញបន្ទាប់ពីលោកបាត់បង់កៅអីរបស់ខ្លួនកាលពីការបោះឆ្នោតឆ្នាំ២០១១។

ថ្លែងសុន្ទរកថា នាឱកាសសម្ពោធការចូលកាន់តំណែងអភិបាលក្រុង អេលៀត បានចង្អុលបង្ហាញជាសាធារណៈនូវខ្លឹមសារពីរសំខាន់ៗគឺសុវត្ថិភាពសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចជាអាទិភាព ។ ចំណែកការអប់រំក៏ជាប្រការសំខាន់ ៕


ក្រុមប្រឹក្សាក្រុងឡូវែល

On a cold and foggy Monday morning in January, the 2014-2015 Lowell City Council was sworn into office, ushering a new era in the Mill City. As is tradition, the first order of business was to elect a new mayor for the term. Long-time city councilor Rodney Elliott was given the gavel after 16 years and long desiring the position.

The council consisted of 5 returning councilors, Rita Mercier who topped the ticket in the November election, Elliott, Edward Kennedy, Bill Martin, and John Leahy who was elected as the vice chairman of the council. First time councilors included Danny Rourke, former Lowell High School Headmaster William "Bill" Samaras, and former Zoning Board member Corey Belanger. Former mayor and councilor Jim Millinazzo also returns to the council after having lost his seat in the 2011 election.

In his inaugural address, Elliott stressed public safety and economic development as two of his primary issues. Elliott identified a recent spike in gun violence as the top public safety concern of his tenure. Elliott also would like to see the city focus on attracting and retaining new businesses to the city. As mayor, he will also serve as chair of the school committee which was also sworn in later that day. Education priorities include striving to improve facilities and student performance.


អភិបាលក្រុងផូឌិត ហ្វូតណាហាហ្គេនខេនីឌី

នៅតំបន់មួយទៀតនៃរដ្ឋម៉ាសាឈូសែតដែលមានប្រជាពលរដ្ឋខ្មែររស់នៅច្រើនដែរនោះ គឺក្រុងលីន Lynn នឹង រីវៃ Revere... តំបន់នោះមានខ្មែររស់នៅប្រមាណជាង១ម៉ឺននាក់។ នៅពេលដែលឡូវែលរបូតតំណាងខ្មែរចេញពីសាលាក្រុងខ្លួន លីននៅរក្សាតំណែងដ៏សំខាន់នេះនៅក្រុងខ្លួនបានយ៉ាងត្រចះត្រចង់ គឺឯកឧត្តម ហុង ណេត ជាក្រុមប្រឹក្សាសាលាក្រុង At large។

the2nd largest Cambodian Community in Massachusetts is Lynn. Lynn City Council and Mayor has sworn in on January 6th, a Cambodian Native,Hong Net,was reelected for second as Councilor-at-Large.


ក្រុមប្រឹក្សាក្រុងលីន


**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

**ផ្សាយពាណិជ្ជកម្ម Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office) |

អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

**អ្នកនិពន្ធកិត្តិយស Contributed Writers:**

Kim Phien, Kim Sos, Mao Chan Somnom, Mam Yin, Richard Howe Esq. Sengly Kong, Ph.D. James Ostis

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

**ជំនួយការរដ្ឋបាល Administrative Assistant**

Sokha Lim

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at $60.00 or 70 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009



Office Space Available in the Beautiful, Historic Hildreth Building!

បន្ទប់ការិយាល័យទំនេរ ក្នុងអគារដ៏ស្រស់ស្អាត របនាបថបុរាណ!

Various sized spaces available. Flexible Lease Terms and Negotiable Build Out.

មានទំហំ តាមជម្រើស ដែលអាចជ្រើសបាន។ ការជួលអាចបត់បែនតាមការព្រមព្រៀង។

សូមទាក់ទងមកកាន់ ចឹសស្ទីន តាមលេខទូរស័ព្ទ

**Call Justin at 617-469-7368 (RENT).**

ផ្តល់ជូនលោកអ្នកក្នុងថ្ងៃនេះ! Available Today!



45 Merrimack Street. Lowell, MA 01852

# Lowell Videos Show 'Roots, Realities, & Dreams'

## Light of Cambodian Children Film wins 2nd prize

ប្រែសម្រួលសង្ខេបដោយ សុខា : ក្នុងការការប្រកួតដេអូ ដែលរៀបចំដោយស្ថាបនិកក្នុងនោះ ដោយ........ប្រវត្តិសាស្រ្តឡូវែលមានខ្មែរចូលរួមប្រកួត ហើយទទួលបានចំណាត់ថ្នាក់លេខ២ ដោយបានទៅលើកញ្ញា សុភាព ធឹម មកពីអង្គការរស្មីកូនខ្មែរ។ ក្នុងកម្ម វិធីនេះលោក សាយ័ន សួន បានទទួលរង្វាន់ជំនួសមុខឱ្យ កញ្ញា សុភាព ។ សូមអានពិស្តារជាភាសាអង់គ្លេស ។

**By: James Ostis**

In 2010, The Fighter showed that the City of Lowell could be a huge hit when it graces the silver screen. Over the course of the last few months, Lowell Heritage Partnership (LHP) has showcased that you don't need a Hollywood budget to use the power of film and video to tell compelling Lowell Stories.



កញ្ញា សុភាព ធឹម

December 19th - The Light of Cambodian Children's Sopheap Theam was named the second prize winner for a local video contest "Roots, Realities and Dreams Community" by Lowell Heritage Partnership, titled "Future Stars Summers in Lowell" highlighting the organization's summer youth camp. Seven finalists were honored with total prizes of over $3000 at a reception hosted by LTC Lowell after a process that ran throughout the summer and fall.



លោក សាយ័ន សួន

The $750 prize was donated to the organization and accepted by LCC director Sayon Soeun on Sopheap's behalf.

Gary Bergeron of Lowell won the contest's $1500 top prize with the music video "Born and Raised in Lowell." The video featured an original song by Michael Noonan and was produced using the equipment at LTC Lowell.

Another nonprofit organization, Habitat for Humanity of Greater Lowell, won the fan favorite award of $250 after an open online voting period during the month of November. All told, four of the prize awards went directly to area nonprofit organizations as Angkor Dance Troupe and the Greater Lowell Community Foundation's Global Goals Fund (as a gift from Elysa Briggs) also received donations.

The Lowell Heritage Partnership video contest was in partnership with Lowell National Historical Park and made possible through a grant of the Theodore Edson Parker Foundation. For more information about LHP initiative, please visit: www.lowellheritagepartnership.org

# January 20, 2014: Martin Luther King Jr. Day

ម៉ាទីន លូទ័រ ឃីង ជីងរ បានត្រូវគេលបធ្វើឃាដថ្ងៃទី៤ មេសា ១៩៦៨ តែមកដល់ឆ្នាំ១៩៨៦ ពលរដ្ឋអាមេរិកាំង បានត្រូវអនុញ្ញាតិឱ្យឈប់សម្រាកការងារ១ថ្ងៃសម្រាប់រំលឹកគុណូបការគុណ លោក ឃីង ជីអរ ដែលបានធ្វើការតស៊ូមតិអហិង្សា ដើម្បីឱ្យជនស្បែកខ្មៅមានសិទ្ធិសេរីភាពស្មើគ្នានឹងជនស្បែកស ។ សន្ទរថាដ៏ល្បីល្បាញរបស់លោក គឺធ្វើឡើងនៅរដ្ឋធានីវ៉ាស៊ីនតោននាឆ្នាំ១៩៦៣ មានឈ្មោះថា "ខ្ញុំមានក្តីស្រម័យ" ដែលបានធ្វើឱ្យលោកបានឈ្នះរង្វាន់"ណូបែល"នៅឆ្នាំ១៩៦៤ ដោយសារតែចលនាអហិង្សា ដើម្បីភាពស្មើគ្នានៃមនុស្សមានសម្បុរស្បែកខុសគ្នានេះ ។

នៅឡូវែលនេះសាលា "យូម៉ាសឡូ"នឹងប្រារព្ធ ពិធីដ៏មានន័យនេះ នៅថ្ងៃទី ២០ មករា ឆ្នាំ២០១៤ នាវេលាថ្ងៃត្រង់នៅ "សុងហ្គាសង់ទ័រ" ៕

**By Richard P. Howe Jr.**

Monday, January 20, 2014 is Martin Luther King Jr. Day. It is a holiday in Massachusetts so schools and government buildings will be closed. The holiday is in honor of Dr. Martin Luther King Jr. who was a leader of the Civil Rights movement in America during the 1950s and 1960s. King delivered his famous "I have a dream" speech in Washington in 1963 and won the Nobel Peace Prize in 1964 for combating racial inequality through nonviolent means. He was assassinated on April 4, 1968 in Memphis, Tennessee.

Martin Luther King Jr. day was made a Federal holiday in 1986 and in 2011 the United States go vernment opened the Martin Luther King Jr. Memorial (shown above) in Washington D.C. The memorial is along the National Mall and is placed midway between the Lincoln Memorial and the Jefferson Memorial.

In Lowell, a celebration of the Life of Dr. Martin Luther King Jr. is organized each year by Lura Smith and Middlesex Community College. This year's event will begin at noon on January 20, 2014 in the lobby of the UMass Lowell Tsongas Center (formerly the Tsongas Arena) and features music, dance and speeches that honor the life and goals of Dr. King.



# ខួបថ្ងៃ៧មករា

**អត្ថាធិប្បាយ :** ឆ្នាំនេះដូចឆ្នាំមុនៗគណបក្សប្រជាជនតែងប្រារព្ធថ្ងៃ៧មករា១៩៧៩ថា "ជាថ្ងៃ



ប្រវត្តិសាស្ត្រដែលក្រុមខ្មែរក្រហមកុម្មុយនីស្តបានត្រូវផ្តួលរំលំបានដោយសម្ព័ន្ធខ្មែរកុម្មុយនីស និងយៀកមិញ" ។ នៅដើមឆ្នាំ២០១៤នេះ ថ្ងៃ៧មករាបានផ្តើមឡើង ដោយស្នាមឈាមកម្មករខ្មែរ ដែលទាមទាររស់ដោយស្មើមុខនឹងគេមានជីវភាពត្រឹមត្រូវ ។ ឈាមហូរដោយស្នាដៃគណបក្សប្រជាជនកម្ពុជានាពេលនេះ បានធ្វើឱ្យគណបក្សដែលដណ្តើមអំណាចបានដោយកម្លាំងបាយ បញ្ចប់ការដាក់កម្ពុជាឱ្យទៅ "និមិត្តរូបនៃជ័យភណ្ឌសង្គ្រាមរបស់ខ្លួនយ៉ាងជាក់ស្តែង" ។

ឈាមកម្មករ និងបាតុករដែលបានហូរលើកនេះធ្វើឡើងនៅចំពោះមុខប្រជាបាតុកររាប់លាននាក់ដែលចេញមកសម្តែងមតិនៅជាមួយគណបក្សសង្គ្រោះជាតិ ថ្កោលទោសនាយករដ្ឋមន្ត្រីបន្តុបឡើងដោយគណបក្សប្រជាជនកម្ពុជាចេញពីដួងចិត្តប្រជាពលរដ្ឋដែលនៅសេសសល់ដោយបណ្តាញឃោសនាអកុសល ហើយ បញ្ចប់ជំនឿថា "ខ្មែរកុម្មុយនីស្ត យៀកមិញ ថាបានបញ្ចប់របបកុម្មុយនីស្តចេញពីកម្ពុជានោះជារឿងភាន់ច្រឡំ" ។




ថ្ងៃ៧មករា លើកនេះ ជាអំណោយផលចុងបញ្ចប់នៃរជ្ជកាលផ្តាច់ការយោធានិយមនៃបក្សប្រជាជន ឱ្យទៅជាអំណាចនៃវត្ថុបំណងពលរដ្ឋខ្មែរ ដែលបានចង់ប្រទេសស្អាតស្អំ ចេះលើកដម្កើងពលរដ្ឋខ្លួនឯង និងឯករាជ្យពីប្រទេសជិតឆ្ងាយ ។ វត្ថុបំណងប្រជាជាតិនោះ កំពុងដើរតម្រង់ទៅរកភាពជោគជ័យដោយអហឹង្សាហើយ ៕

**ខ្មែរប៉ុស្តិ៍ស.រ.អា**







## តមកពីទំព័រទី ១ គណបក្សសង្គ្រោះជាតិសង្ឃឹមរក...

ឡើងយ៉ាងរន្ធើនជាប្រតិសាស្ត្រនៅទីក្រុងភ្នំពេញ ក៏ប៉ុន្តែនៅដើមឆ្នាំ២០១៤វិញរដ្ឋាភិបាលលោក ហ៊ុន សែន បានបាត់បង់ការព្យាយាមរក្សាអហឹង្សា ផ្តើមប្រើយោធាប្រដាប់អាវុធ តាមទម្លាប់ចាស់បាញ់សម្លាប់កូដកររោងចក្រអហឹង្សាអស់៥នាក់នឹងរបួសប្រមាន៣០នាក់ផ្សេងទៀត ធ្វើឱ្យជំនួបបច្ចេកទេសគណបក្សប្រជាជននឹងគណបក្សសង្គ្រោះជាតិ ដើម្បីរកដំណោះស្រាយបច្ចេកទេសចំពោះវិបត្តកម្ពុជាបានត្រូវខកខានគួរឱ្យស្តាយ ។

គួររំលឹកថា សប្តាហ៏បញ្ចប់នៅថ្ងៃទី២៧ធ្នូ ២០១៣នេះ គឺជាសប្តាហ៏ប្រកបដោយកំណត់ប្រវត្តិសាស្ត្រនយោបាយថ្មីទៀត ដោយសារព្រឹត្តិការណ៏បង្ករបាតុកម្មដ៏ធំបង្អស់ពេញមួយអាទិត្យមួយសម្តែងមតិដោយពលរដ្ឋខ្មែរនឹងគណបក្សតាមបច្ចេកទេសអហឹង្សារបស់គណបក្សសង្គ្រោះជាតិតែមានកម្លាំងដ៏ខ្លាំងខ្លា គួរឱ្យភ័យខ្លាច ជាពិសេសចំពោះគណបក្សប្រជាជនរបស់លោក ហ៊ុន សែន ដែលត្រូវបានបាតុកររាប់លាននាក់ប្រទេចផ្តាសារនៅគ្រប់ទីកន្លែង ។ ជាទម្លាប់បាតុកម្មរបៀបនេះប្រាកដជាទទួលបាននូវការបង្ក្រាបយ៉ាងសាហាវនាពេលមុនៗហេតុអ្វីក៏ពេលនេះ បែរជាស្ងប់ស្ងាត់គ្មានប៉ូលិសដំបងឆក់មួយគ្រាប់គ្មានឡានទឹកស្អុយ...

អ៊ីចឹងចម្លើយមាន២យ៉ាង ១-បើតាមលោក ផៃ ស៊ីផាន អ្នកនាំពាក្យរដ្ឋាភិបាលថា នេះជាលទ្ធផលនៃនយោបាយលោក ហ៊ុន សែន ដែលបានផ្តល់ជូនសេរីភាពនៃការសម្តែងមតិដល់ប្រជាពលរដ្ឋ ២-មហាបាតុកម្មដែលផុះផុលភ្លាមៗកើនធំហួសពីកម្លាំងបង្ក្រាបរបស់រដ្ឋាភិបាលលោក ហ៊ុន សែនទេ ២-ចរចាក្នុងន័យបន្លាយពេល៥ឆ្នាំសម្រាប់រៀបចំយុទ្ធវិធីថ្មី ។ មិនត្រឹមតែគេមិនជឿទេ ថែមទាំងគណបក្សសង្គ្រោះ ជាតិមិនទុកឱកាសឱ្យគណបក្សប្រជាជនដក ដង្ហើមបានទៀតផង ដោយធ្វើបាតុកម្មរាល់ថ្ងៃពេញ ១អាទិត្យធំៗសម្បើម មិនដែលមាននៅស្រុកខ្មែរគឿងគរបន្ថែមកម្មកររាប់ម៉ឺននាក់ឱ្យចេញពី រោងចក្រប្រមូលបាតុករដ៏ធ្លីបានជោគជ័យនេះជាកត្តាបំភ័យយ៉ាងជាក់ស្តែងដល់មន្ត្រីដែលមានខ្លួនខិលខូចក្រុមអ្នកឧកញ៉ាពាណិជ្ជករ ជាពិសេសមន្ត្រីរាជការ យោធាប៉ូលិស ផ្តើមសង្ស័យថា "របបបច្ចុប្បន្ននឹងដួលរលំនៅពេលឆាប់ៗនេះ" ។







ប្រសិទ្ធភាពនៃជំនួបមនុស្ស២នាក់ គឺ សម រង្ស៊ី និង កឹម សុខា ដែលគេជឿជាក់ពីប្រវត្តិស្មោះត្រង់ចំពោះជាតិបណ្តាលឱ្យមានការគាំទ្រពីបណ្តាពលរដ្ឋច្រើនហួសពីការស្មានហួសពីទម្លាប់ដែលថាខ្មែរចេះតែឈ្លោះគ្នាមិនចេះរួបរួមគ្នាទេ ហួសពីប្រជាប្រិយភាពរបស់អតីតព្រះមហាក្សត្រនរោត្តម សីហនុ ទៅទៀតនោះ ប្រាកដជាមាន

តទៅទំព័រទី ២៣

"សង្គ្រោះជាតិ" នៅកណ្តាលក្រុងភ្នំពេញតែម្តង។ បាតុកម្មដែលបានសម្រេចប្តេីមធ្វើជារៀងរាល់ថ្ងៃនៅទីលានប្រជាធិបតេយ្យជាមួយពលរដ្ឋប្រមាណ ១ម៉ឺននាក់នាថ្ងៃទី២០ធ្នូ ទាមទារឱ្យរដ្ឋាភិបាល ហ៊ុន សែន រកយុត្តិធម៌ឱ្យម្ចាស់ឆ្នោត -បន្ទាប់មកបានក្លាយទៅជាបាតុកម្មជាមួយពលរដ្ឋប្រមាណ ១សែននាក់ នាថ្ងៃបន្ទាប់ទាមទារឱ្យ ហ៊ុន សែន លាចេញពីដំណែងនាយករដ្ឋមន្ត្រី និងឱ្យមានការបោះឆ្នោតសារជាថ្មី-មកដល់ថ្ងៃអាទិត្យ ទី២៧ធ្នូ បាតុករបានឡើងចំនួន១លាននាក់ ដោយមានការចូលរួមបន្ថែមពីចលនាសហជីពកម្មកររោងចក្រប្រមាណ៣០ម៉ឺននាក់ ដែលមិនសប្បាយចិត្តនឹងរដ្ឋាភិបាលពុករលួយមិនអាចឱ្យមានការតម្លើងប្រាក់ខែគ្រប់គ្រាន់ឱ្យកម្មករបាន ក៏បណ្តាលឱ្យមានការទាមទារ ១-"ជីវភាព១៦០ដុល្លាមួយ ខែឱ្យកម្មករភ្លាម" ២-"ហ៊ុន សែន ចុះចេញពីដំណែង" ៣-"បោះឆ្នោតសាកលសារជាថ្មី" ។ ឯកទត្តកម្មលើទំហំចូលរួមនៃបាតុករមិនសប្បាយចិត្តបានធ្លាក់មកក្នុងដៃគណបក្សសង្គ្រោះជាតិជាបន្តបន្ទាប់មិនត្រឹមតែប៉ុណ្ណោះពលរដ្ឋខ្មែរនៅបរទេសក៏មានការគាំទ្រយ៉ាងពេញទំហឹងណាស់ដែរ បានធ្វើឱ្យគណបក្សសង្គ្រោះជាតិក្លាយជា "អ្នកដឹកនាំភ្លេងឱ្យគណបក្សប្រជាជនរាំវិញម្តង"ជាលើកដំបូងទៅហើយ ។ បាតុកម្មដែលទទួលការទិទានថា មានការរោឃៅតយ៉ាវពីពេលមុន ឥឡូវបានត្រូវសង្ឃឹមតម្រូវឱ្យមានការប្តូរស្មៀតទៅជាត្រជាក់ទៅវិញ។ ចម្លើយទី២ទំនងជាសមស្របជាងដោយសារតាំងពីមុនបោះឆ្នោតមកទល់ពេលនេះ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន មានការច្រឡំច្រើនក្នុងការសម្រេចចិត្តធំៗ ដូចជាព្រមឱ្យ សម រង្ស៊ី ចូលស្រុកទឹកថា គណបក្សសង្គ្រោះជាតិនឹងរៀបខ្លួនឃោសនាបោះឆ្នោតមិនទាន់ពេលទេ ឬថា បច្ចេកទេសបំបែកបំបាក់ផ្ទៃក្នុងសត្រូវ និងមានប្រសិទ្ធភាពដូចសព្វមួយដង ឬក៏ថា ប្រជាពលរដ្ឋនៅតែខ្លាចការគម្រាមរបស់ ហ៊ុន សែន តែដដែលដូចមុន... ។ល។ ហ៊ុន សែន បានមើលស្រាលនូវសម្ព័ន្ធភាពគណបក្ស សម រង្ស៊ី នឹងគណបក្សសិទ្ធមនុស្ស ហើយយើងធ្លាប់បាននិយាយហើយថា "បើទុកឱ្យបាតុកម្មផ្តើមហើយវានឹងមិនចប់រហូតដល់ ហ៊ុន សែន ធ្លាក់ពីអំណាច ហើយបើមានការប្រើយុទ្ធវិធីបង្ក្រាបបង្ហូរឈាមពេលនេះ វានឹងរំលាយគណបក្សប្រជាជនទាំងមូលតែម្តងបានទៀតផង" ។

ប្រសិទ្ធភាពការធ្វើសេចក្តីសម្រេចចិត្តច្រឡំនេះ រួមគ្នានឹងជំនឿថា គណបក្សប្រជាជនបានចាញ់ឆ្នោតមែននោះ បានបង្រួញការគាំទ្រលោកនាយករដ្ឋមន្ត្រីពីសំណាក់មិត្តភ័ក្តិក្នុងគណបក្សប្រជាជនដែលបានភ័យស្លន់ស្លោ ហើយត្រៀមឱបក្រសោបទ្រព្យសម្បត្តរត់នឹងកាពារក្រុមគ្រួសារខ្លួន ដូច្នេះដើម្បីស្រោចស្រង់កំហុសនេះមានតែ ១-ធ្វើឱ្យគេជឿថាគ្រប់គ្រងប្រទេសតែម្នាក់ឯងគ្មានបញ្ហាអ្វី



# ឌឹ ខេមបូឌា ដេលី The Cambodia Daily

ជំនឿចម្រៃសរំលពីអាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បតិ៍ ទី០៩ ខែមករា ឆ្នាំ២០១៣

## អង្គការសិទ្ធិមនុស្សនៅទីក្រុងប៉ារីសថ្កោលទោស ចំពោះការបាញ់សម្លាប់អ្នកតវ៉ាពីសំណាក់អាជ្ញាធរ

**By Denise Hruby - January 8, 2014**

The International Federation for Human Rights (FIDH), along with local released in Paris on Monday.

"The killing of demonstrators by government authorities is totally unacceptable.



rights groups Licadho and Adhoc, denounced the Friday shooting of protesting garment workers by police in a joint statement

The government must use dialogue, not guns and batons, to address workers'

**តទៅទំព័រទី ១៣**

## វីរៈបុរសដែលគួរចងចាំ

**ដោយ : ខ្មែរផុស**

ដកស្រង់ពីសៀវភៅប្រវត្តិសាស្ត្រកម្ពុជា និង វីរជនខ្មែរ អ្នកនិពន្ធ សាគូ សាម៉ុត

គ្រឹះស្ថានបោះពុម្ពផ្សាយ-បណ្ណាគារ អង្គរ ភ្នំពេញ ទូរស័ព្ទលេខ ០១២ ៤៥៥ ៨៨៥





### ព្រះបាទ ជ័យវរ្ម័ន ទី៧ (១១៨១-១២០៨) និង ការស្ថាបនា អង្គរធំ

**១- ការរំឭកសង្ខេប នូវប្រវត្តិសាស្ត្រដើម**

នៅឆ្នាំ ១១៧៧ទ័ពចាម ដឹកនាំដោយស្តេចពានរាជ្យ ចាម ព្រះនាមព្រះជយោឥន្ទ្រវរ្ម័ន ទី៤ បានវាយសម្រុកកាន់កាប់ព្រះរាជធានីអង្គរ ដោយទីក្រុងឥតបានដឹងខ្លួនមុន ហើយបានធ្វើគត ព្រះរាជាពានរាជ្យខ្មែរ ព្រះនាមត្រីភូវនទិត្យវរ្ម័ន ដែលគ្រងរាជ្យនៅទីក្រុងអង្គរ នៅគ្រានោះ ។ គឺជាលើកដំបូងហើយ ដែលព្រះរាជធានី យសោធរបុរៈ បានត្រូវខ្មាំងក្រៅប្រទេសចូលមកកាន់កាប់ ។ រហូតមកទល់នឹងពេលនេះ ទំនប់ការពារព្រះរាជធានី គឺផ្អែកច្រើនទៅលើបារមី នៃ ជំនឿសាសនា ជាងទៅលើបច្ចេកទេសយោធា ។ រីឯខ្សែក្រវាត់ទឹក ដែលហ៊ុំព័ទ្ធជុំវិញអង្គរវិញ ក៏មិនមែនធ្វើឡើងសម្រាប់ការពារប្រាសាទ ដូចជាខ្សែក្រវាត់ទឹកដែលការពារជំណាក់នៅប្រទេសអឺរ៉ុបទេ ។ ខាងវិស័យយោធា ព្រះរាជធានី មិនបានទទួលការការពារហ្មត់ចត់ឡើយ ហើយបរាជ័យនៅចំពោះមុខខ្មាំង គឺពេញលេញទាំងស្រុង ។ អត្ថបទ

**តទៅទំព័រទី ១៤**

## រដ្ឋាភិបាលពេលនេះនៅតែមិនទាន់ប្រាប់ពីទីកន្លែងឃុំខ្លួនអ្នកតវ៉ាដែលត្រូវបានចាប់ខ្លួន

**ដោយ Kuch Naren and Aun Pheap - January 8, 2014**

មេធាវីការពារក្តីម្នាក់ និងសកម្មជនការពារសិទ្ធិមនុស្សបានដឹងឱ្យថា កាលពីម្សិលមិញមន្ត្រីតុលាការ និងមន្ត្រីពន្ធនាគារបានបន្តលាក់បាំងទីតាំងរបស់មនុស្សចំនួន២៣នាក់ដែលត្រូវបានចាប់ខ្លួន អំឡុងការតវ៉ារបស់កម្មករកាត់ដេរ ដែលកំពុងធ្វើកូដកម្មក្នុងរាជធានីភ្នំពេញកាលពីសប្តាហ៍មុន។



មនុស្ស១០នាក់រួមមានមេដឹកនាំសហជីពនិងសកម្មជននយោបាយត្រូវទាហានចាប់ខ្លួនកាលពីថ្ងៃព្រហស្បតិ៍។ ហើយមនុស្ស១៣នាក់បន្ថែមទៀត ត្រូវកងរាជអាវុធហត្ថចាប់ខ្លួនកាលពីថ្ងៃសុក្រ អំឡុងពេលបង្ក្រាបលើការតវ៉ាមួយដែលបណ្តាលឱ្យកម្មករកាត់ដេរចំនួនប្រាំនាក់បានបាត់បង់ជីវិតដោយសារត្រូវគ្រាប់កាំភ្លើងពិត។

លោក អំ សំអាត អ្នកស៊ើបអង្កេតជាន់ខ្ពស់នៅអង្គការសិទ្ធិមនុស្សលីកាដូបានឱ្យដឹងថា ក្រុមគ្រួសារ និងមេធាវីរបស់អ្នកដែលត្រូវគេចាប់ខ្លួនទាំងនោះនៅមិនទាន់ត្រូវបានគេប្រាប់ឱ្យដឹងពីដំណឹងណាមួយនៅឡើយទេ។

លោក សំអាត បានមានប្រសាសន៍ថា "មកទល់នឹងថ្ងៃនេះយើងនៅមិនទាន់ទទួលបានដំណឹង

**តទៅទំព័រទី ១៩**

## Arrested Protesters' Whereabouts Still Unknown

**By Kuch Naren and Aun Pheap - January 8, 2014**

Prison and judicial officials on Tuesday continued to conceal the whereabouts of 23 people who were arrested during protests by striking garment workers in Phnom Penh last week, rights workers and a defense lawyer said.

Ten people, including union leaders and political activists, were arrested by soldiers on Thursday. A further 13 were arrested by military police on Friday during the suppression of a protest that saw five striking workers shot dead.

Am Sam Ath, senior investigator with rights group Licadho, said the family and lawyers of those detained were still being refused their requests for any information.

"Up to today, we have had no information about their whereabouts," Mr. Sam Ath said. "All of our defense lawyers—and the relatives—have also confirmed that they still are not aware of the whereabouts of the clients."

"There are still rumors circulating that they are being held at CC3 or CC4," Mr. Sam Ath added, referring to correctional centers 3 and 4—large prisons located in the provinces of Pursat and Kompong Cham respectively.

"Our staff will go down to the prison in Kompong Cham province [CC3] tomorrow to check."

Choung Choungy, defense lawyer for six of the arrested, said he would submit a request for bail on behalf of his clients at the Phnom Penh Municipal Court today but was also being kept in the dark about his clients' location.

Chan Soveth, senior investigator with local rights group Adhoc, said that he too believed the 23 were being held at the notorious Kompong Cham prison.

A joint statement released by Licadho and the Cambodian Legal Education Center on Monday described CC3 as being **Continued to Page19**

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ ព្រហស្បត្តិ៍ ទី០៩ ខែមករា ឆ្នាំ២០១៣

# ការនាំចេញអង្កររបស់កម្ពុជាទៅបរទេសកើនឡើង ជាង១៧០.០០០តោននៅក្នុងឆ្នាំ២០១៣

*By Hul Reaksmey - January 3, 2014*

Rice exports increased from 205,717 tons in 2012 to 378,856 tons in 2013 as a result of high demand from the European Union as well as countries in Asia, according to figures released Thursday by the Ministry of Agriculture.

France imported the most Cambodian milled rice, followed by Poland, Malaysia, the Netherlands, China and Thailand, according to the figures.

ការនាំចេញអង្ករបានកើនឡើងពីចំនួន ២០៥.៧១៧តោន ក្នុងឆ្នាំ២០១២ ដល់៣៧៨.៨៥៦តោនក្នុងឆ្នាំ២០១៣ដោយសារតែមានតម្រូវការខ្ពស់ពីសហភាពអឺរ៉ុប ព្រមទាំងនៅប្រទេសមួយចំនួននៅអាស៊ីផងដែរ នេះបើយោងតាមតួលេខដែលក្រសួងកសិកម្មបានបញ្ចេញកាលពីម្សិលមិញ។

យោងតាមតួលេខដដែលនេះប្រទេសបារាំងបាននាំចូលអង្ករកម្ពុជាច្រើនជាងគេបង្អស់ បន្ទាប់មកប្រទេសប៉ូឡូញ ប្រទេសម៉ាឡេស៊ី ប្រទេសហូឡង់ ប្រទេសចិន និងប្រទេសថៃ។

លោក ហ៊ាន វណ្ណហន អគ្គនាយករងនៃអគ្គនាយកដ្ឋានកសិកម្មរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានមានប្រសាសន៍ថា កាលពីឆ្នាំមុនប្រមូលផលស្រូវបានចំនួនប្រហែល ៩.៣៤លានតោន គឺកើនឡើងពី៩.២៩លានតោនក្នុងឆ្នាំ២០១២។ លោកបានមានប្រសាសន៍ទៀតថា ពានរង្វាន់សម្រាប់អង្ករផ្កាម្លិះ ជាអង្ករល្អបំផុតក្នុងពិភពលោកបានជួយដល់ស្ថានភាពស្រូវអង្ករ និងបានធ្វើឱ្យការនាំចេញកើនឡើង។ លោកលើកឡើងថា "ប្រទេសកាន់តែច្រើនចាប់ផ្តើមស្គាល់អង្ករកម្ពុជាជារៀងរាល់ថ្ងៃ"។






លោក លីម ប៊ុន ហេង ប្រធានសហព័ន្ធនាំអង្ករចេញបានមានប្រសាសន៍ថា ការនាំចេញអង្ករពីប្រទេសកម្ពុជាបានកើនឡើងក្នុងរយៈពេលពីរបីឆ្នាំចុងក្រោយនេះដោយសារការទទួលស្គាល់របស់អន្តរជាតិ។

លោកមានប្រសាសន៍ថា "ឱ្យប្រទេសផ្សេងៗកំពុងចាប់ផ្តើមស្គាល់អង្កររបស់យើង ។ ការបញ្ជាទិញបន្តកើនឡើង"។ លោកបានបន្តថា ក្រុមហ៊ុនឡូរ៉ង់គ្រុបរបស់លោកបាននាំចេញអង្ករ២២.០០០តោនក្នុងឆ្នាំ២០១៣ គឺកើនឡើងពី៥.៧០០តោនក្នុងឆ្នាំ២០១២។ លោកបានមានប្រសាសន៍ថា "ខ្ញុំនឹងព្យាយាមបង្កើនការនាំចេញអង្កររបស់ខ្ញុំទ្វេដង" នៅឆ្នាំនេះ។

ប៉ុន្តែលោក លីម ប៊ុនហេង បានមានប្រសាសន៍ថា ខណៈដែលតម្រូវការអង្ករនៅទូទាំងពិភពលោកកើនឡើងរោងម៉ាស៊ីនកិនស្រូវនានានៅក្នុងស្រុកកំពុងជួបបញ្ហាក្នុងការទទួលបានឥណទានពីធនាគារសម្រាប់បន្តប្រតិបត្តិការ។ លោកបានមានប្រសាសន៍ថា "ធនាគារពាណិជ្ជមួយចំនួនឱ្យយើងខ្ចីតែ៦០ទៅ៧០ភាគរយប៉ុណ្ណោះនៃទ្រព្យសកម្មរបស់យើង រីឯធនាគារខ្លះទៀតឱ្យយើងខ្ចីតែ៥០ភាគរយ ឬពី៣០ទៅ៣៥ភាគរយ"៕

**សុខុម**

---

តមកពីទំព័រទី ១២

## អង្គការសិទ្ធិមនុស្សនៅទីក្រុងប៉ារីស...

demands and to deal with political dissent," FIDH president Karim Lahidhi said in the statement.

នៅក្នុងសេចក្តីថ្លែងការណ៍រួមមួយដែលបានចេញផ្សាយក្នុងក្រុងប៉ារីសកាលពីថ្ងៃច័ន្ទសហព័ន្ធសិទ្ធិមនុស្សអន្តរជាតិ (FIDH) ព្រមទាំងអង្គការសិទ្ធិមនុស្សក្នុងស្រុកអាដហុក និងលីកាដូ កាលពីថ្ងៃសុក្របានថ្កោលទោសចំពោះការបាញ់កម្មកររោងចក្រកាត់ដេរដែលបានធ្វើការតវ៉ាពីសំណាក់អាជ្ញាធរ។

លោក ការីម ឡាហ៊ីធី ប្រធាន FIDH បានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នោះថា

"ការបាញ់សម្លាប់បាតុករពីសំណាក់អាជ្ញាធររដ្ឋា ភិបាលមិនអាចទទួលយកបានឡើយ។ រដ្ឋាភិបាលត្រូវតែប្រើប្រាស់ការចរចាមិនមែនប្រើអាវុធ និងដំបង ដើម្បីដោះស្រាយការទាមទាររបស់កម្មករ និងដើម្បីដោះស្រាយជាមួយអ្នកប្រឆាំងផ្នែកនយោបាយបែបនេះឡើយ"។

កាលពីព្រឹកថ្ងៃសុក្រ កងរាជអាវុធហត្ថបានបាញ់ទៅលើកម្មកររោងចក្រកាត់ដេរមួយក្រុមដែលធ្វើការតវ៉ាទាមទារដំឡើងប្រាក់ខែគោល។ អ្នកតវ៉ាបានបិទផ្លូវមួយក្នុងខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ហើយបានគប់ដុំថ្មដាក់កងរាជអាវុធហត្ថដែលបានបាញ់កាំភ្លើងអាកា-៤៧តបវិញដោយប្រើគ្រាប់ពិតធ្វើឱ្យកម្មករប្រាំនាក់ស្លាប់ និងរបួសជាច្រើននាក់ទៀត។ អង្គការអាដហុកបានទាមទារឱ្យមានការស៊ើបអង្កេតពីការបាញ់សម្លាប់នេះ។

លោក ធន សារាយ ប្រធានអង្គការសិទ្ធិមនុស្សអាដហុកបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍នេះថា "រដ្ឋាភិបាលត្រូវធ្វើការស៊ើបអង្កេតឱ្យបានឆាប់ ដោយហ្មត់ចត់ និងដោយឯករាជ្យចំពោះការបាញ់កាលពីថ្ងៃទី៣ ខែមករាកន្លងមកនេះ ហើយត្រូវទទួលខុសត្រូវចំពោះហេតុការណ៍នោះ"។

បើទោះណាមានសាក្សី រូបថត និងរូបភាពវីដេអូអំពីការបាញ់នោះ ក៏ដោយ ក៏លោកឧត្តមសេនីយ៍ត្រី ខេង ទិតូ អ្នកនាំពាក្យកងរាជ អាវុធហត្ថ បានបដិសេធថា កងកម្លាំងរបស់រដ្ឋាភិបាលមិនទទួលខុសត្រូវចំពោះការស្លាប់នោះឡើយ ហើយបានលើកឡើងថា ក៏មិនមានការស៊ើបអង្កេតពីហេតុការណ៍នោះដែរ។ ក្រសួងការបរទេសបារាំងសមាជិកសភា និងជាប្រធានគណៈកម្មការកិច្ចការបរទេសអាមេរិក និងអង្គការសហប្រជាជាតិក៏បានថ្កោលទោសចំពោះការប្រើអំពើហិង្សារបស់អាជ្ញាធរកាលពីពេលថ្មីៗនេះដែរ។ **សារុន**

08 មករា 2014 / 08 Jan. List of the six garment factory workers, all male, killed by the armed forces on 03 Jan. 2014បញ្ជីរាយនាមកម្មករ ភេទប្រុស ទាំង៦នាក់ ដែលត្រូវកងកម្លាំងប្រដាប់អាវុធបាញ់សម្លាប់ កាលពីថ្ងៃទី ០៣ ខែមករា ២០១៤ (មានបញ្ជាក់ទាំងអាយុ និងស្រុកកំណើត) :- យាន រិទ្ធី (អាយុ២៥ឆ្នាំ ខេត្តព្រៃវែង) Yean Rithy, ២៥- ខេង កុសល (អាយុ២៣ឆ្នាំ ខេត្តកំពង់ចាម) Kheng Kosol, ២៣- គឹម ផល្លី (អាយុ២៦ឆ្នាំ ខេត្តកំពង់ស្ពឺ) គិម Phally, ២៦- ស្រេង វិបុល (អាយុ២២ឆ្នាំ ខេត្តកណ្តាល) Sreng Vibol, ២២- អ៊ុក ភ័ក្រ (អាយុ២៣ឆ្នាំ ខេត្តព្រៃវែង) Ouk Pheak, ២៣- សម រ៉ាវី (អាយុ ២៦ឆ្នាំ ខេត្តតាកែវ) Sam Ravy, ២៦

# K-PHARMANCY IS OPENED




ឱសថស្ថានខ្មែរដ៏ធំជាងគេបង្អស់នៅឡូវែល ឈ្មោះ "ខេហ្វាម៉ាស៊ី" បានបើកសម្ពោធន៍កាលពីថ្ងៃទី២៨ខែធ្នូ ឆ្នាំ២០១៣ ដោយមានការចូលរួមកាត់ខ្សែបូពីលោកចៅហ្វាយក្រុង ប៉ាទ្រីត ម៉រហ្វី-លោកសមាជិកក្រុមប្រឹក្សាក្រុង និងសមាជិកសហគមន៍ប្រមាណជា៥០នាក់ទៀត ។

ស្ថិតនៅលេខ២៨០ផ្លូវវ៉េសហ្វឺត គឺជាតំបន់កណ្តាលនៃទីក្រុងខ្មែរនាំឱ្យមានការងាយស្រួលដល់សហគមន៍ខ្មែរមកទិញថ្នាំសង្កូវនៅឱសថស្ថានដែលបើកបំរើអតិថិជន៧ថ្ងៃក្នុងថ្ងៃអាទិត្យ ។

*ដោយ:ជេម អទិស*

Over the years, Lowell has become a hub for Cambodian-owned businesses in the United States, but surprisingly, the city has never had a Cambodian-owned independent pharmacy. But that all changed on December 28th, as the City of Lowell celebrated the grand opening of K-Pharmacy on Westford St. Mayor Patrick Murphy, City Councilor Vesna Nuon, and a crowd of about 50 community members were in attendance for the celebration, which included a ceremonial ribbon-cutting and remarks from the officials gathered there.

The recent trend in Lowell and other cities has been a decline in independent pharmacies as national chains have taken on an even bigger share of the market. K-Pharmacy's status as a locally owned business reverses a trend. The Westford St location is convenient for many residents of the Lower Highlands, including Murphy who noted it was a convenient walk for him. The full-service pharmacy also sells many food, drink, and household items.

With over 10 years of experience in retail pharmacy and English and Khmer speaking staff, K Pharmacy is the largest Khmer pharmacy in Lowell. K Pharmacy is located at 280 Westford St in Lowell and is open 7 days a week.





តមកទំព័រទី ១២ វីរៈបុរសដែលគួរចងចាំ



ទាហានខ្មែរ



ទូកងផ្ទុកកងទ័ពចាមដែលកំពុងឈ្លានពានវាយយករាជធានីអង្គរ

ចិនមួយ បាននិយាយចំពោះព្រឹត្តិការណ៍នេះ ដូចតទៅ : "ស្តេចចាម បាននាំទ័ពនាវាចរ ចូលមកដល់ព្រះរាជធានី ប្រទេសចេនឡា ដោយទីក្រុងនេះមិនបានដឹងខ្លួនមុន ហើយបាន កំទេចទីក្រុងនេះខ្ទេចខ្ទីអស់ ព្រមទាំង ធ្វើគតព្រះចៅក្រុងកម្ពុជា ដោយមិនព្រមស្តាប់នូវ សំណើរចរចា ដើម្បីសន្តិភាពសោះ ។ នេះបង្កើតឲ្យខ្មែរមានគំនុំមួយយ៉ាងធំ ដែលនឹងត្រូវ បានទទួលផ្លែផ្កានៅឆ្នាំទី ៥ នៃ សក្ករាជ គឺឯយន់ (១១៩៩)" ។

## ២- រជ្ជកាល ព្រះបាទជ័យវរ្ម័ន ទី៧

តាមរយៈព្រះមាតា ព្រះនាមជូដមានី ព្រះបាទជ័យវរ្ម័ន ត្រូវភ្ជាប់ព្រះអង្គ ទៅជាមួយនឹងព្រះរាជវង្សមុនសម័យអង្គរ ហើយតាមរយៈព្រះបីតា ព្រះបាទតារានិន្ទ្រវរ្ម័ន ទី២ ទៅជាមួយនឹងព្រះរាជវង្ស មហិតារាបូរា ។ ព្រះអង្គ ត្រូវជាចៅក្មួយ ព្រះបាទសូរិយាវរ្ម័ន ទី២ គឺខ្លួនព្រះអង្គនេះហើយ ដែលត្រូវទទួលភារកិច្ចយ៉ាងទំងន់បំផុត ដើម្បីរំដោះប្រទេសកម្ពុជាឲ្យ "ដកខ្លួនផុតពីសមុទ្រគ្រោះអាសន្ន" គឺការកាន់ពីកណ្តាប់ដៃចាម ។

ក្រោយពីព្រះអង្គបានទទួលដំណឹងពីអនិច្ចកម្ម នៃ ព្រះបីតាព្រះអង្គ ព្រមទាំង ការពានរាជ្យពីសំណាក់ ត្រីភូវនទិត្យវរ្ម័ន ដំណាលគ្នានឹងការបាត់ខ្លួន នៃ ព្រះបាទយសោ-វរ្ម័ន ទី២ ដែលជាក្សត្រគ្រងរាជ្យដោយស្របច្បាប់ អនាគត ព្រះបាទ ជ័យវរ្ម័ន ទី៧ ដែលកំពុងតែហ៊ុំព័ទ្ធទីក្រុងវិជ័យ នៃ ប្រទេសចម្ប៉ា ក៏បានប្រញាប់ប្រញាលវិលត្រឡប់មក


# ការិយាល័យច្បាប់នៃមេធាវីម៉ារីណា ស្សេបជល្គី ភី សី

LAW OFFICES OF MARINA SHEPLSKY,P.C.

*Attorneys at Law* មេធាវីច្បាប់
Member of NY and NJ Bar
សមាជិកគណមេធាវីរដ្ឋញូយ៉ក និង ជឺស៊ី

109 Lafayette st. ste C-5
New york, NY 10013

Tel : 212-219-2299
E-Mail: marina@shepelskylaw.com



MARINA SHEPLSKY,Esq KENNY SENG

REPRESENTING IMMIGRATION CLIENTS IN ALL 50 STATES

ការិយាល័យច្បាប់នៃមេធាវីម៉ារីណា សេ្សបផលស្គី អាចជួយលោកអ្នកក្នុងផ្នែកអន្តោប្រវេសន៍ដូចខាងក្រោម :

- គ្រីនខាត តាមរយ:ការរៀបអាពាហ៍ពិពាហ៍ និងសមាជិកគ្រួសារ
- សេចក្តីអនុញ្ញាតក្នុងនាមគូដណ្តឹង
- សេចក្តីអនុញ្ញាតក្នុងនាមគ្រួសារ
- អ្នកដែលមិនទាន់ចូលសញ្ជាតិ ហើយប្រឈមនឹងការបញ្ជូនត្រលប់ទៅស្រុកវិញ
- ការចាប់ខ្លួន និងដកហូតអន្តោប្រវេសន៍ (អន្តោប្រវេសន៍ពន្ធនាគារ)
- ជនភៀសខ្លួន និងការសុំអនុញ្ញាតជ្រកកោន
- ទិដ្ឋាការសម្រាប់វិនិយោគិន
- ការសុំសិទ្ធិញ្ញឹមជាអន្តរជាតិ
- ទិដ្ឋាការធ្វើការ និងជំនួញ
- ការសម្ភាសជាមួយ យូ អេស ស៊ី អាយ អេស
- ទិដ្ឋាការស្នាក់នៅរយ:ពេលខ្លី ឬបណ្តោះអាសន្ន
- ភាពជាពលរដ្ឋនៃសហរដ្ឋអាមេរិក និងការសុំចូលសញ្ជាតិ
- ការប្តឹងឧទ្ធរណ៍
- ការតវ៉ា ដើម្បីបើកសវនាការក្តីដែលបានបិទរួចហើយ

**បំពេញសុបិន្តអាមេរិកលោកអ្នក**
**ឱ្យក្លាយជាការពិតតំណាងកូនក្តីទូទាំង៥០រដ្ឋ**

រាល់សេចក្តីត្រូវការផ្នែកច្បាប់អន្តោប្រវេសន៍ សូមចូលកាន់គេហទំព័រ WWW.E-US-VISA.COM

WWW.SHEPELSKYLAW.COM

# ជនជាតិខ្មែរដំបូងបំផុតដែលរស់នៅក្រុងឡូវែល

**ដោយៈ រីឆាដ ហូវ**

*៦សីហា ឆ្នាំ២០១៣*

*ប្រែសម្រួលដោយ ហេង លីមហ៊ាង*

៥០ឆ្នាំកន្លងទៅប្រជាជនក្នុងតំបន់ឡូវែលមិនសូវស្គាល់ជនជាតិនៃភូមិភាគអាស៊ីអាគ្នេយ៍ប៉ុន្មានឡើយ។ ក្រោយមកបុរសវ័យក្មេងម្នាក់ត្រូវបានចាត់តាំង និងបញ្ជូនឱ្យទៅច្បាំងក្នុងសង្គ្រាមក្នុងប្រទេសវៀតណាម ហើយមួយចំនួនបានពលិកម្មជីវិតក្នុងសង្គ្រាម។ ផ្លូវ អ័រខិន ដ្រៃវី (Arcand Drive) ជាផ្លូវដែលគិតចាប់ពីសាលាក្រុងឡូវែល City Hall ទៅសុងហ្គាសអារេណា Tsongas Arena ។ ឈ្មោះផ្លូវអ័រខិន ដ្រៃវី (Arcand Drive) នេះ គឺយកតាមឈ្មោះនាយទាហាន ភី អេហ្វ ស៊ី ដូណល អ័រខិន PFC Donald Arcand ដែលបានស្លាប់នៅអាយុ២០ឆ្នាំពេលដែលឧទ្ធម្ភាចក្រយោធារបស់លោកត្រូវបានបាញ់ទម្លាក់នៅថ្ងៃទី១ ខែកញ្ញា ឆ្នាំ១៩៦៥។ សួនខាឡឺរី ឬ (Callery Park) តាមបណ្តោយផ្លូវស្ទេវិន (Stevens) និង វ៉ាលឌឺ (Wilder) នៅសង្កាត់ ហៃឡែន (High Land) ត្រូវបានដាក់ឈ្មោះដោយយកតាមឈ្មោះរបស់លោក វីល្លៀម ធី . ខាឡឺរី (William T. Callery) ដែលបានស្លាប់ក្នុងអគ្គិភ័យ នាថ្ងៃទី២២ខែកុម្ភៈ ឆ្នាំ ១៩៩៦ នៅអាយុ ២១ឆ្នាំ។

នៅពេលដែលសង្គ្រាមរវាងអាមេរិក និងវៀតណាមត្រូវបានបញ្ចប់ក្នុងអំឡុងឆ្នាំ១៩៧០ ប្រជាជនក្នុងតំបន់ឡូវែលគិតថា អនាគតនៃទំនាក់ទំនងរវាងឡូវែល និងអាស៊ីអាគ្នេយ៍អាចនឹងជានិមិត្តរូបនៃការប្រាស្រ័យទាក់ទងរវាងជាតិទាំងពីរនេះដើម្បីរំឭកដល់អ្នកដែលបានស្លាប់ក្នុងគ្រានោះ។

ជនភៀសខ្លួនដំបូងដែលមកពីភូមិភាគអាស៊ីអាគ្នេយ៍មកដល់តំបន់ឡូវែលចុងឆ្នាំ១៩៧០។ ភាគច្រើននៃអ្នកទាំងនោះជាជនជាតិវៀតណាម តែខ្លះជាឡាវ និងខ្លះទៀតជាខ្មែរ។ ការធ្វើជំរឿនប្រជាជននៅឆ្នាំ១៩៨០ នៅតំបន់ឡូវែលបានឱ្យឃើញថា មានត្រឹម២ទៅ៣នាក់ប៉ុណ្ណោះក្នុងចំណោម១០០នាក់ ដែលមកពីភូមិភាគអាស៊ីអាគ្នេយ៍ដែលរស់នៅក្នុងតំបន់ឡូវែល។ មនុស្សមួយក្រុមតូចពីភូមិភាគអាស៊ីអាគ្នេយ៍ដែលមកដល់ឡូវែលដំបូងគេបង្អស់ជាប្រភពដ៏សំខាន់។ ទោះជាយ៉ាងណាក៏ដោយមិនយូរប៉ុន្មាន ក៏មានសេចក្តីត្រូវការក្នុងការបង្កើតឱ្យមានការប្រកបរបរជំនួញតូចៗសមាគមបម្រើប្រយោជន៍សហគមន៍វត្តអារាម និងមជ្ឈមណ្ឌលផ្សេងៗទៀត ដើម្បីជ្រោមជ្រែងសហគន៍នៃជនអន្តោប្រវេសន៍ទាំងនេះ។ ជាច្រើនឆ្នាំបន្តបន្ទាប់មកទៀត ម្តងបន្តិចៗលំហូចូល នៃជនជាតិខ្មែរ និងឡាវ មានសម្ទុះគួរឱ្យកត់សម្គាល់។



Richard Howe

ក្នុងឆ្នាំ១៩៨៦លំហូរចូលនេះ មានកាន់តែច្រើនឡើង។ "អច្ឆរិយម៉ាសាឈូ សេត" ឬ "Massachusetts Miracle" បានឃើញកំណើនសេដ្ឋកិច្ចនៃរដ្ឋនេះ ខណៈដែលរដ្ឋផ្សេងៗក្នុងសហរដ្ឋអាមេរិកទទួលរងញាំញីដោយកំណើននៃភាពអត់ការងារធ្វើ។ ម្ល៉ោះហើយជនភៀសខ្លួនមកពីភូមិភាគអាស៊ីអាគ្នេយ៍ដែលបានតាំងលំនៅក្នុងរដ្ឋផ្សេងៗប្រញាប់ប្រញាល់ផ្លាស់ប្តូរលំនៅរបស់ខ្លួនមកតាំងនៅតំបន់ឡូវែលវិញ ព្រោះជាកន្លែងសំបូរដោយការងារព្រមទាំងមានសហគន៍ខ្មែរតាំងនៅតំបន់នោះរួចជាស្រេច។




ក្នុងឆ្នាំ១៩៨៧ ការធ្វើស្ថិតិតាមរបៀបមុនៗបានបង្ហាញថា អ្នកតាំងលំនៅអចិន្ត្រៃយ៍ក្នុងតំបន់ឡូវែលចំនួន៣០០០នាក់ មកពីប្រទេសឡាវ និងច្រើនជាងមួយម៉ឺនប្រាំបីពាន់នាក់ (១៨០០០នាក់) មកពីព្រះរាជាណាចក្រកម្ពុជា (ប្រទេសខ្មែរ)។ តួរលេខក្រោយមកទៀត នៃចំនួនប្រជាជនខ្មែរនៅឡូវែលមានប្រមាណបីម៉ឺននាក់ (៣០០០០ នាក់) និងអាចច្រើនជាងនេះ។ ទន្ទឹមនឹងភាពសំបូរនៃការងារកំណើនដ៏ខ្ពស់នៃអ្នកតាំងលំនៅថ្មីក្នុងពេលដ៏ប្រថុចញ៉ុចបានបង្កើតឱ្យមានបញ្ហាលំបាកមួយចំនួនដល់ប្រជាជនរស់នៅទីនោះ ពិសេសគឺថ្លៃជួលផ្ទះ។ តែបញ្ហាសំខាន់មួយទៀត ចោទឡើងក្នុងសាលាសាធារណៈនានា ក្នុងតំបន់ឡូវែលត្រូវជួបនឹងឧបសគ្គក្នុងការស្វែងរកគ្រូបង្រៀននិយាយពីរភាសា និងថ្នាក់រៀនទំនេរសម្រាប់ផ្តល់ឱ្យសិស្សជាច្រើនដែលមកចុះឈ្មោះរៀនរាល់សប្តាហ៍។

នៅដើមឆ្នាំ១៩៨៧ មន្ទីរអប់រំរបស់រដ្ឋបានផ្តល់នូវជំនួយឧបត្ថម្ភភ្លាមៗ និងអនុញ្ញាតឱ្យកូនសិស្ស១៦០នាក់ ដែលនិយាយពីរភាសា គឺអាស៊ីនិងអេស្ប៉ាញឱ្យប្រើប្រាស់ថ្នាក់រៀននៅ វ៉ាយ អ៊ឹម ស៊ី អេ (YMCA) និងនៅដឹបយស៍ខ្លឹប (The Boys Club) ដើម្បីឱ្យកូនសិស្សទាំងនោះ ទទួលបាននូវការប្រើប្រាស់សម្ភារៈបរិក្ខាក្នុងសាលាឱ្យដូចសាលាទូទៅដទៃទៀតនៅពេលដែលគេផ្តើមចូលរៀន ។ ខាងរដ្ឋនៃសហរដ្ឋអាមេរិកក៏ទាមទារឱ្យក្រុងឡូវែលបង្កើតប្រព័ន្ធអប់រំមជ្ឈមណ្ឌលមួយដែលផ្តោតការចាប់អារម្មណ៍ទៅលើការប្រកាន់ពូជសាសន៍ដែលរីកសាយធំឡើងក្នុងប្រព័ន្ធអប់រំដែលមានក្នុងក្រុងឡូវែល។

គណៈកម្មាធិការក្នុងសាលាព្រមទាំងមាតាបិតាសិស្សមួយក្រុមតូចដែលភាគច្រើនមានជាតិកំណើតអេស្ប៉ាញបដិសេធក្នុងការអនុម័តនូវគម្រោងនេះ។ ប៉ុន្តែអាស្រ័យដោយការគាំទ្រពីសំណាក់ជនជាតិមកពីភូមិភាគអាស៊ីអាគ្នេយ៍ និងមន្ទីរយុត្តិធម៌អាមេរិកបានដាក់ពាក្យបណ្តឹងទល់នឹងក្រុងឡូវែលនៅតុលាការសហព័ន្ធ។

ខណៈដែលសំណុំរឿងត្រូវបានពន្យារពេលនៅបរវេសនកាលឆ្នាំ១៩៨៧ប្រជាជនក្នុងក្រុងឡូវែលបោះឆ្នោតជ្រើសរើសគណៈកម្មាធិការថ្មីក្នុងសាលា។ ក្នុងរយៈពេលដ៏ខ្លីការប្រាស្រ័យទាក់ទងរវាងមាតាបិតាសិស្សនៃក្រុមជនជាតិភាគតិចដូចជាខ្មែរ ឡាវ និងប្រព័ន្ធសាលារដ្ឋចាប់ផ្តើមប្រសើរឡើង។ បន្ទាប់ពីការចរចាដ៏យូរបណ្តឹងត្រូវបានដោះស្រាយ **តទៅទំព័រទី ១៨**

# The early Cambodian residents of Lowell

By Richard P. Howe Jr.
August 6, 2013

Fifty years ago people in Lowell knew little about Southeast Asia but then young men from here were drafted and sent to fight in Vietnam. Some of them died there. Arcand Drive, which runs from Lowell City Hall to the Tsongas Arena, is named for PFC Donald Arcand who died at age 20 when his Army helicopter was shot down on September 1, 1965. Callery Park, which lies between Stevens and Wilder Streets in the Highlands, is named for William T. Callery who was killed by hostile fire on February 22, 1966. He was 21.

When America's involvement in the Vietnam War ended in the 1970s, people in Lowell assumed that the only future connection between the city and Southeast Asia would be the local monuments and plaques erected in memory of those who died there. No one imagined how wrong that assumption would prove to be.

The first refugees from Southeast Asia arrived in Lowell in the late 1970s. They were mostly from Vietnam but some were from Laos and Cambodia. A 1980 census found fewer than 100 people from Southeast Asia living in Lowell. That early group was resourceful, however, and quickly established small businesses, community support organizations, a temple and the other things needed to create a thriving immigrant community. Over the years, a small but steady stream of Cambodians and Laotians came to Lowell.

In 1986, however, that stream became a flood. The "Massachusetts Miracle" saw this state's economy booming while the rest of the country suffered from high unemployment and economic stagnation. Southeast Asian refugees who had settled in other parts of America were soon moving to Lowell, attracted by plentiful jobs and the already vibrant Cambodian community in the city.

By 1987, conservative estimates held that Lowell's residents included 3,000 people from Laos and more than 18,000 from Cambodia. Later estimates said that number was as high as 30,000. While there were plenty of jobs, such a large number of new residents arriving in such a short time created strains on people and resources, especially rental housing. But the greatest impact was on the Lowell public schools which struggled to find space and bilingual teachers for the dozens of new students who were enrolling each week.

In early 1987, the state department of education granted an emergency waiver that allowed Lowell to place 160 bilingual students, both Hispanic and Asian, in rented rooms at the YMCA and the Boys Club on the condition that the city would bring those students into regular facilities at the beginning of the new school year. The state also demanded that the city implement a central enrollment system that would begin to address the racial segregation that had arisen in the Lowell school system.

The school committee refused to adopt such a plan and so a group of parents, mostly Hispanic but with the support of many Southeast Asians and the U.S. Department of Justice, filed a lawsuit against the city in federal court.

While that lawsuit was pending, the people of Lowell in the fall of 1987 elected several new school committee members. Almost immediately, relations between the minority parents and the public school system began to improve. After countless hours of negotiations, the lawsuit was settled and the city adopted a central enrollment system that would desegregate the schools. As a result of this plan being adopted, Lowell moved to the top of the state's school building assistance program and by the early 1990s, more than a dozen brand new schools had been built with the state paying 90% of the cost.

Today, Cambodian people are an integral part of the Lowell community and for many, the events of 1987 seem like ancient history. But it is important to understand that things might have ended differently if many people of good will from all groups had not come together and struggled for outcomes that were in the best interest of all residents of Lowell. It is a lesson worth remembering today.

# Cambodia Town of Lowell

By Sengly Kong , Ph.D, Chairperson of Cambodia Town Committee



In 2010, the City of Lowell designated a Cambodia Town in order to officially recognize the Lowell Cambodian American community's contribution over the past three decades to revitalizing the partially blighted lower highland neighborhood and to elevate interest in the area's stores and restaurants, attract new businesses, bring in tourists, and increase civic pride.

The designation was a timely response to the aspiration of the community and businesses as reflected in their positive responses to a brief survey in early 2010 conducted by the Cambodian Mutual Assistance Association (CMAA) of the greater Lowell. In October 29, 2011, a Cambodia Town Committee, an organization of volunteers, was set up with the support of the Cambodian community and businesses; and the Committee works closely with the City and other community based organizations to advance a vision of economically, culturally vibrant and prosperous Cambodia Town of Lowell.

Lowell is home to the second largest Cambodian American community in the United States after Long Beach, California. According to Richard Howe, co-author of a book: Legendary locals of Lowell, Cambodian refugees were attracted in large numbers to Lowell by relatively plentiful jobs in the mid 1980s and the already vibrant Cambodian community in the city. According to the 2010 US Census, Lowell has about 22,000 Cambodians; however, it is widely agreed that Cambodians in Lowell were seriously undercounted. Community leaders, who live and work for decades in the community, estimated that there are approximately 35-40,000 Cambodians about one third of the city population; the estimate is quite consistent with extrapolated school enrollment data. As the result, Lowell has a large proportion (20.2%) of Asians compared to only 5.3% statewide and also has a high proportion (14.8%) of Asian-owned business versus 4.5% statewide (Census 2010).

There are at least 200 Cambodian American businesses of all sizes and kinds most of which are concentrated in the Cambodia Town. Cambodian restaurants are ubiquitous; each offers a variety of authentic ethnic dishes, and it also tends to have its signature dish based on customer preference. For example, customers usually like a sour beef stew (Samlor Machu Sach Koa) at Red Rose restaurant or roasted duck at Phnom Penh restaurant or steamed soy sauce Tilapia (Trey Cham Hoy) at Mekong restaurant or Rice Field Sour Fish Soup (Samlor Machu Srae) at Piphup Thmei restaurant. All ingredients are authentic and found at local Grocery Supper Markets: Phnom Penh Market on Branch Street, Hong Kong Market on Westford, and Bangkok Market on Chelmsford Street etc.

Authentic jewelry stores are also omnipresent throughout the Cambodia Town. You can find, for example, Asian Jewelry on Westford Street, and Phnom Pich Jewelry or Pailin Jewelry or Apsara Jewelry on Middlesex etc. You can buy necklace with lucky charmed pendant or bracelet with artistic design or earrings of Angkorian style or contemporary Cambodian fashion. During summer weekends, you can see traditional wedding receptions at Cambodian restaurants with bride and groom wearing a set of dazzling jewelries; wedding crown, costumes, and changing each set every hour throughout the evening. Traditional wedding is customarily organized in two parts; the first part isorganized in a morning at a bride's home with invited monks chanting blessings for a couple. The reception is generally held in the evening with invited guests from both sides: the bride's side and the groom's. If interested, one can also buy traditional costumes, jewelry, lucky charms, and other souvenirs at local costume and souvenirs shops throughout the Town.




Religion plays important roles in most Cambodian American life. From birth to death, Cambodians involve Buddhism one way or another. Buddhist monks are, for example, invited to chant blessing for a newborn although this practice is rare nowadays. There are usually Buddhist ceremonies throughout a year: Phjum Ben, New Year, funeral etc each of which involves monks chanting blessing. Three Buddhist temples offer religious services in Lowell; one temple, known as Glory Buddhist temple, is located in the Cambodia Town off Chelmsford Street while two others, Trairatanaram and Khmer Lowell Temple, are in neighboring community. There are score of other cultural entities that make Lowell Cambodia Town culturally vibrant. Cambodian Mutual Assistance Association provides culturally appropriate social services; Metta Health Clinic of Lowell Community Health Center provides culturally competent health-care services; Angkor Dance Troup and Tep Niyum Musical offer classical and folk dances for various occasions etc.

In sum, Cambodia Town offers great opportunities for tourists to experiences authentic cultures and for investors to invest in new businesses, and for Cambodian Americans to be proud of. Visiting the Cambodia Town of Lowell gives you not only great memorable experiences, but also help promote sustainable economic growth that would help this former refugee community to realize its vision of economically, culturally vibrant and prosperous Cambodia Town. The Lowell Cambodia Town can be easily accessible from either I-494 exit 35 A-B-C or Route 3 or I-93; it can also be accessed through a 40-minute ride by commuter rail from Boston's North Station.

តមកទំព័រទី ១៩ ជនជាតិខ្មែរដំបូងបំផុតដែលរស់នៅ...

ហើយក្រុងឡូវែលអនុម័តប្រព័ន្ធចុះឈ្មោះមជ្ឈមណ្ឌល (Central Enrollment System) ដែលអាចកាត់បន្ថយ និងលុបបំបាត់នូវគម្លាតជាតិសាសន៍ និងការរើសអើងក្នុងសាលា។ ជាលទ្ធផលគម្រោងនេះត្រូវបានអនុម័ត ហើយក្រុងឡូវែលវិវត្តខ្លួនជាសាលារដ្ឋដ៏ល្អបញ្ចូលកម្មវិធីជំនួយផ្សេងៗក្នុងកម្មវិធីរបស់សាលា។ ត្រឹមដើមឆ្នាំ១៩៩០ សាលាថ្មីៗជាច្រើនត្រូវបានសាងសង់ ដុះដាលហើយចំណាយថវិការដ្ឋដល់ទៅ៩០%។

សព្វថ្ងៃនេះ ប្រជាជនខ្មែរជាល្បាយជាតិសាសន៍ដ៏ចម្បងក្នុងសហគមន៍ឡូវែល ហើយប្រវត្តិព្រឹត្តិការណ៍កើតឡើងអំឡុងឆ្នាំ១៩៨៧ទំនងក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្ររបស់ខ្មែរទាក់ទិននឹងក្រុងឡូវែល។ យ៉ាងណាមិញចំណុចដ៏សំខាន់ដែលគួរយល់ដឹង គឺលទ្ធផលខាងលើអាចបញ្ចប់ក្នុងរូបភាពផ្សេងពីនេះ ប្រសិនបើពុំមានការចូលរួមពីក្រុមមនុស្សនិងជាតិសាសន៍ផ្សេងៗទៀត ដែលមានឆន្ទះល្អពួតដៃជាមួយខ្មែរ និងជនជាតិអាស៊ីអាគ្នេយ៍ផ្សេងទៀតដែលព្យាយាមតស៊ូទាមទារប្រយោជន៍ដល់អ្នករស់នៅក្នុងឡូវែល។ នេះជាករណីសិក្សា និងជាមេរៀនដ៏សំខាន់ដែល គួរចងចាំជាទីបំផុតមកដល់សព្វថ្ងៃនេះ៕

តមកពីទំព័រទី ១២
# រដ្ឋាភិបាលពេលនេះនៅតែមិនទាន់...

ណាមួយពីទីតាំងរបស់ពួកគេនៅឡើយទេ។ មេធាវីការពារក្តីទាំងអស់របស់យើង និងសាច់ញាតិរបស់អ្នកដែលត្រូវគេចាប់ខ្លួនក៏បានបញ្ជាក់ដែរថា ខ្លួននៅមិនទាន់ទទួលបានដំណឹងពីទីតាំងរបស់កូនក្តីខ្លួននៅឡើយទេ"។

លោក សំអាត បានបន្ថែមថា "នៅតែមានពាក្យចចាមអារ៉ាមថា ពួកគេកំពុងត្រូវបានឃុំឃាំងនៅមណ្ឌលកែប្រែ៣ និងមណ្ឌលកែប្រែ៤ ដែលជាពន្ធនាគារដ៏ធំនៅក្នុងខេត្តពោធិ៍សាត់និងខេត្តកំពង់ចាម។

លោកបានមានប្រសាសន៍បន្ថែមទៀតថា "បុគ្គលិករបស់យើងនឹងចុះទៅពន្ធនាគារនៅក្នុងខេត្តកំពង់ចាមនៅថ្ងៃស្អែកដើម្បីត្រួតពិនិត្យ"។

លោក ជួង ជូងី មេធាវីការពារក្តីរបស់មនុស្សចំនួនប្រាំមួយនាក់ដែលត្រូវបានចាប់ខ្លួនបានលើកឡើងថា លោកនឹងដាក់សំណើរទៅកាន់សាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃនេះដើម្បីស្នើសុំឱ្យមានការដោះលែងឱ្យ នៅក្រៅឃុំជួសមុខឱ្យកូនក្តីរបស់ខ្លួន ប៉ុន្តែលោកនៅតែមិនទាន់ដឹងថា តើកូនក្តីរបស់លោកស្ថិតនៅទីណានោះទេ។

លោក ចាន់ សុវ៉េត អ្នកស៊ើបអង្កេតជាន់ខ្ពស់នៅអង្គការសិទ្ធិមនុស្សអាដហុកបានលើកឡើងថា លោកក៏ជឿជាក់ថា មនុស្សដែលត្រូវគេចាប់ខ្លួនទាំង២៣នាក់នោះកំពុងត្រូវបានគេឃុំឃាំងនៅក្នុងពន្ធនាគារខេត្តកំពង់ចាមដែលគេល្បីថា ជាពន្ធនាគារធ្វើបាបអ្នកទោស។



សេចក្តីថ្លែងការណ៍រួមមួយចេញដោយអង្គការលីកាដូ និងមជ្ឈមណ្ឌលអប់រំច្បាប់កម្ពុជា កាលពីថ្ងៃច័ន្ទ បានរៀបរាប់ថា មណ្ឌលកែប្រែ ៣គឺស្ថិតនៅក្នុងចំណោមពន្ធនាគារដែលលំបាកបំផុតមួយចំនួននៅក្នុងប្រទេសកម្ពុជា។

លោក គា សុវណ្ណា ប្រធានមណ្ឌលកែប្រែ៣ បានបដិសេធ កាលពីថ្ងៃ ច័ន្ទថា អ្នកទោសមិននៅទីនោះឡើយ ប៉ុន្តែគេមិនអាចទាក់ទងលោកបានឡើយកាលពីម្សិលមិញ។

លោក សុក សំអឿន ប្រធានក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា ជាអង្គការក្រៅរដ្ឋាភិបាលផ្តល់ជំនួយផ្លូវច្បាប់បានលើកឡើងថា លោកមិនធ្លាប់ឃើញករណីស្រដៀងគ្នានេះនៅក្នុងប្រទេសកម្ពុជាឡើយចាប់តាំងពីអង្គការសហប្រជាជាតិបានរៀបចំការបោះឆ្នោតជាតិក្នុង ឆ្នាំ១៩៩៣មក។

លោក សំអឿន បានមានប្រសាសន៍ថា "នេះ គឺជាបញ្ហាមួយដែលបានកើតឡើងជាញឹកញាប់អំឡុងទសវត្សរ៍ឆ្នាំ ១៩៨០ ហើយនេះប្រហែលជាយើងបានត្រឡប់ទៅកាន់សម័យនោះវិញហើយមើលទៅ"។

លោកបានបន្ថែមទៀតថា "ឱ្យក្នុងពេលបច្ចុប្បន្ន ជួនកាលពួកគេមិនអនុញ្ញាតឱ្យអ្នកទោសទាក់ទងមេធាវីឬសមាជិកក្រុមគ្រួសាររបស់ខ្លួនឡើយ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយនៅថ្ងៃណាមួយ?ពួកគេនៅតែមិនអាចលាក់បាំងពីទីកន្លែងឃុំឃាំងអ្នកទោសទាំងនោះបានឡើយ"៕

**ស៊ុយ ឈាង**

Continued from Page 12
# Arrested Protesters' Whereabouts Still...

"among the harshest prisons in Cambodia."

CC3 director Kea Sovanna refused to confirm or deny on Monday that the prisoners were there, but could not be reached Tuesday.

Sok Sam Oeun, director of the Cambodian Defenders Project, a legal aid NGO, said that he had not seen a similar case in Cambodia since the U.N. supervised elections here in 1993.

"This is the kind of problem that happened during the 1980s quite often, and so perhaps this means we have gone back to that period," Mr. Sam Oeun said.

"[Now] sometimes they do not allow the prisoners to contact their lawyer or family member, but even then they would still not hide from people where they were held."


## កម្មវិធីថែសុខភាពតាមគេហដ្ឋានសម្រាប់ចាស់ៗ និងជនពិការភាព

- នាងថែខ្ញុំដូចជាម្តាយបង្កើត ខ្ញុំសប្បាយចិត្តណាស់
- នាងស្រឡាញ់និងថែខ្ញុំដូចជីដូនបង្កើត
- នាងចំអិនម្ហូប បោសសំអាតផ្ទះ បោកខោអាវ ហើយស្តាប់រឿងខ្ញុំពេលខ្ញុំកើតទុក្ខ
- ខ្ញុំមានពេទ្យមកពិនិត្យសុខភាពជាប្រចាំ
- នាងរលឹកពេលដែលខ្ញុំត្រូវញាំថ្នាំ គ្រប់ពេលវេលា
- នាងជូនខ្ញុំដើរលេងលំហែកាយ
- នាងជួយខ្ញុំទិញម្ហូបនិងសំភារៈប្រើប្រាស់
- កូនខ្ញុំមិនព្រួយអំពីភាពអត់ការងារធ្វើ ហើយបាននៅក្បែរខ្ញុំគ្រប់ពេលវេលា
- ព្រឹទ្ធាចារ្យជាដុំពេជ្យក្នុងសង្គមយើង ចូរអ្នកទាំងអស់ខំថែទាំគាត់អោយមានអាយុវែងនិងសុខភាពល្អ។

ក្រុមហ៊ុនយើងខ្ញុំកំពុងជ្រើសរើសបុគ្គលិកធ្វើការ
សម្រាប់ពត៌មានបន្ថែមអំពីកម្មវិធីនេះសូមទាក់ទង

ម៉ូនីដា (២៦៧) ២៦២-៣៩២៩ ដេវីដ (២៦៧) ៩១៨-៨៤៩៣

HOME CARE
Aurora



# រមណីយដ្ឋានធម្មជាតិ ដ៏ស្រស់ស្អាត និង ទាក់ទាញបំផុត អូរស្វាយ



បូរីអូរស្វាយស្ថិតក្នុងឃុំអូរស្វាយ នៃស្រុកថាឡាបូរីវ៉ាត ហើយទីនេះគឺជារមណីដ្ឋានមួយក្នុងចំណោមរមណីដ្ឋានពេញនិយមជាច្រើនទៀត ដែលភ្ញៀវទេសចរជាតិ និងអន្តរជាតិតែងតែមានបំណងចង់មកទស្សនា។ តំបន់នេះគឺជាផ្នែកមួយនៃរាជធានីអាណាចក្រខ្មែរ បុរាណ និងរាប់បញ្ចូលទាំងរ៉ាំសា (តំបន់អភិរក្សលិចទឹក) ដែលមានសត្វផ្សោតជាច្រើនរស់នៅតាមបណ្តោយទន្លេមេគង្គ សត្វបក្សាបក្សី សត្វព្រៃ ជាច្រើនរស់នៅតំបន់ព្រៃឈើអភិរក្សដែលរាជរដ្ឋាភិបាលអណត្តិថ្មីបានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ ស្ពានយោល វត្តអារាម ដោយរាប់បញ្ចូលទាំងផ្ទះសំណាក់សាធារណៈ (ផ្ទះសម្រាប់ស្នាក់នៅ) មជ្ឈមណ្ឌលព័ត៌មាន និងកំពង់ផែទូកសម្រាប់ភ្ញៀវទេសចរ។ល។ រមណីដ្ឋាន បូរីអូរស្វាយ ប្រៀបបាននឹងត្បូងពេជ្រដ៏មានតម្លៃ ដែលបានផុសឡើងនៅក្នុងទ្រូងព្រៃត្រពិចពណ៌បៃតង ដែលលាតសន្ធឹងតាមបណ្តោយទន្លេមេគង្គ។ វាបានផ្តល់នូវសម្បត្តិព្រៃឈើដ៏ប្រសើរដែលជាជំរកដ៏ប្រសើរសម្រាប់សត្វព្រៃ។ ជាពិសេសហ្វូងបក្សាបក្សី និងជាជម្រកត្រីដ៏ប្រសើរ ក្នុងរដូវវស្សា ហើយមានត្រីផ្សោតដ៏ច្រើនដែលពេញនិយមសម្រាប់ភ្ញៀវទេសចរ។ នៅរដូវប្រាំងពេលទឹកស្រកទីនេះបានរំលេចឱ្យឃើញនូវឆ្នេរខ្សាច់ពណ៌សដ៏ស្រស់ស្អាតដែលលាតសន្ធឹងតាមបណ្តោយដងទន្លេ គួរឱ្យចង់ដើរលេងកំសាន្ត ហើយក៏មានព្រែកជាច្រើនដោយមានព្រែកខ្លះមានទឹកហូរលឿន ចំណែកព្រែកខ្លះទៀតក៏មានទឹកហូរយឺត។ ចំណែកឯព្រៃចំការស្វាយក៏បានរំលេចទេសភាពស្រស់ត្រកាល តាមបណ្តោយដងទន្លេជាមួយថ្មផុសដែលបានលេចឡើងយ៉ាងស្រស់ស្អាត។ នៅ តាមបណ្តោឆ្នេរទន្លេដែលមានទេសភាពស្រស់ត្រកាល និងព្រែកដែលមានទឹកហូរខ្ចួលខ្ចាញ់ជាញាប់គេតែងតែឃើញមានដានជើងសត្វព្រៃដែលមកទីនេះនៅពេលយប់។ នៅទីនេះមានទឹកមានល្បឿនលឿនថ្លាល្អ និងធ្លាក់ចុះមកក្នុងកំពស់ប្រាំម៉ែត្រ។ ទឹកដែលហូរធ្លាក់ជាមួយល្បឿនដ៏លឿននេះ បានផ្តល់ឱ្យទីនេះមានទេសភាពល្អប្រណិត គួរជាទីគយគន់សម្រាប់ភ្ញៀវ ទេសចរមកងូត និងហែលទឹកកំសាន្តយ៉ាងសប្បាយរីករាយ។ នៅតាមបណ្តោយទន្លេមេគង្គក្នុងឃុំស្វាយតំបន់អភិរក្សដីល្បាប់រ៉ាំសា ត្រូវបានការពារដោយច្បាប់ជាពិសេសតំបន់ត្រីពង ដែលជាទីកន្លែងផ្តល់នូវការបង្កកំណើតដល់ត្រីរាប់លានក្បាល សត្វបក្សា បក្សី និងសត្វព្រៃដ៏ទៃទៀតព្រមទាំងមានដើមឈើជាច្រើនប្រភេទផ្តល់ឱ្យតំបន់នេះក្លាយជាតំបន់អេកូឡូស៊ីដ៏ធំមួយ។ ចំណែកឯផ្លូវថ្នល់បានតភ្ជាប់ពីភូមិមួយទៅភូមិមួយទៀតដោយនៅតាមដងផ្លូវមានរុក្ខជាតិដុះអមសងខាងចោលម្លប់ត្រឈឹងត្រឈៃ ព្រមទាំងឆ្លងកាត់ចរន្តទឹកហូរ និងព្រែកទាំងឡាយដែលមានទឹកហូររលេញគួរជាទីភិសម័យ។ តំបន់ព្រៃភ្នំទាំងនេះត្រូវបានអភិរក្សប្រៀបបាននឹងឋានសួគ៌សម្រាប់អ្នកបររទេះ និងអ្នកជិះកង់ក្នុងព្រៃអាចស្តាប់ឮតន្ត្រីធម្មជាតិនៃសម្លេងសត្វបក្សាបក្សីយំខ្សៀវខ្សា និងពេលខ្លះបានឃើញសត្វព្រៃរត់ឆ្លងកាត់យ៉ាងសប្បាយរីករាយ។ ឃុំអូរស្វាយមានភូមិចំនួន៥ (ភូមិ អូរស្វាយ ភូមិអូររុន ភូមិកោះព្នៅ ភូមិកោះ ហីប និង ភូមិរៀន សែន ) មានចំនួនផ្ទៃដី ១២០.០00ហិកតា និង រាប់បញ្ចូលកោះបួនថែមទៀត។ ឃុំនេះមានប្រជាជនសរុបទាំងអស់ចំនួន៦៥៨១នាក់ ហើយ ៨0ភាគរយ គឺជាកសិករ និងអ្នកនេសាទ ហើយពួកគេប្រកបរបរនេះតាមបណ្តោយព្រំប្រទល់កម្ពុជា,ឡាវ ។ ឃុំអូរស្វាយមានចំងាយ៥៧ គីឡូម៉ែត្រពីផ្លូវជាតិលេខ៧ និងអាចធ្វើដំណើរតាមទន្លេមេគង្គដែលហូរឆ្ពោះទៅទិសពាយព្យនៃក្រុងស្ទឹងត្រែង៕







# តមកពីទំព័រទី ៣ ដំណើរតាមជើងសមុទ្រ"អាតាឡង់ទិក"



នៅសល់អ្វីដែលយើងមិនឃើញតែមានដែរនោះ គឺចំណីចំណុកសែសសល់ជាសម្រាមជាសំណល់បង្គន់ បើចោលក្នុងទឹកសមុទ្រម្លេះសមពុលត្រីសត្វសមុទ្រ មិនសល់ទេ ព្រោះនាវាដូចគ្នានេះមានច្រើនណាស់ តែគេបានពិព័ណនាក្នុងការផ្សាយរបស់គេអំពីកាកសំណល់រាប់តោនដែលចោលទៅវិញនោះ យកទៅបញ្ចូលមាស៊ីនចម្រាញ់ដាក់ថ្នាំ បំបែកជាសំណល់គោកគ្រឿងក្រខ្វក់ទាំងអស់ត្រូវបញ្ជូនទៅចោលនៅដីគោកវិញទាំងអស់ ។ រីឯផ្សែងវិញក៏មានការប្រុងប្រយ័ត្នជូនភ្ញៀវខ្លាំងណាស់ដែរ មិនត្រឹមតែផ្សែងបារីតែប៉ុណ្ណោះទេ សូម្បីតែបំពង់ផ្សែងធំៗរបស់នាវា ក៏មិនឃើញបញ្ចេញផ្សែងកាបូនីកទៅបំពុលបរិយាកាសផងទេ ។ មហានាវានៅតែរំកិលខ្លួនទៅមុខយ៉ាងយឺតៗជានិច្ចជ្រែកសមុទ្រសំខៅឈ្លូងសមុទ្រ "រដ្ឋហ្វ្លរីដា" ដដែល ដែលកំដៅនឹងពន្លឺថ្ងៃកំពុងក្លាយជាវត្ថុដ៏មានតម្លៃសម្រាប់អ្នកដែលមកពីទីត្រជាក់ នាអាមេរិកខាងជើងរាប់ទាំងភ្ញៀវមកពីកាណាដាផងដែរ ម្លោះហើយនៅជាន់ទី ១៥-១៦ នឹង១៧ ដែលជាដំបូលចំហរនៃនាគសមុទ្រភ្ញៀវជាច្រើនបានឆ្លៀតឱកាសមកដកដង្ហើមយកខ្យល់អាកាសដ៏បរិសុទ្ធមកកំដៅថ្ងៃ ឬមកហាត់ប្រាណ បើទោះជាខ្យល់នៅត្រជាក់បន្តិចនៅឡើយក្តី ។ ដោយសារសីតុណ្ហភាពនៅទាបនៅឡើយនោះ គេពុំទាន់បើកអាងហែលទឹកកន្លែងកំសាន្តទម្លាក់ខ្លួនតាមទរទឹកទាំងតូចទាំងធំ នាកំពូលនាវាមិនឱ្យប្រើនៅឡើយ តែសន្យាថានឹងបើកឡើងជូនភ្ញៀវកំសាន្តនៅថ្ងៃស្អែក។ ភ្ញៀវជាង៤ពាន់នាក់ មកពីគ្រប់ទីសទីមានភ្ញៀវដើមកំណើតអាស៊ីប្រហែលពាក់កណ្តាលច្រើននិយាយភាសាចិនមានពួកស្បែកសមួយចំនួនបន្ទាប់មកមានពួកដើមកំណើតឥណ្ឌាពួកស្បែកខ្មៅឯទៀតៗមានមិនច្រើនទេ ចំនួននេះបើបូករួមនឹងពួកពាណិជ្ជករដែលមកលក់ដូរនៅក្នុងនាវាសិល្បករដន្ត្រីនារិក ព្រមទាំងបុគ្គលិកទទួលនឹងបំរើភ្ញៀវ ថ្វីត្បិតតែគេនិយាយថា មានជាតិសាសន៍៧០ប្រទេសមកធ្វើការតែមុខមាត់អ្នកអាស៊ីអគ្នេយ៍មិនតិចជាង៧០ភាគរយ គួរឱ្យភ្ញាក់ផ្អើលរួមទាំងអស់មានប្រមាណជិត៧ពាន់នាក់ ។ យើងយល់ថា ចំនួនបុគ្គលិកអាស៊ីច្រើនយ៉ាងនេះប្រាកដជាមិនមែនមកពីប្រាក់បៀវត្សថោក ដូចដែលយើងធ្លាប់ឮនោះទេ គឺមកពីជំនាញនៃវប្បធម៌អាស៊ីដែលពូកែរញញឹមយ៉ាងទន់ភ្លន់ គួរសមឱនលំទោនអត់ធ្មត់អធ្យាស្រ័យមានសិល្បៈចង់ធ្វើអ្វីឱ្យប្រសើរជាងគេនៅក្នុងឈាម ហើយមានចំណេះនឹងនិយាយច្រើនភាសាច្បាស់លាស់ផង ហ្វីលីពីន ឥណ្ឌា ឥណ្ឌូនេស៊ី ម៉ាឡេ ចិន ហាក់ដូចជាប្រជាប្រិយច្រើនជាងគេ ។ ភ្ញៀវដែលត្រូវគេលើកដំកើងដូចស្តេចនោះ ក៏ព្រោះតែអ្នកបំរើតាមភោជនីយដ្ឋានទាំងប្រមាណ១០ទាំង ក៏រិតអន្តរជាតិ "បា" បំរើភេសជ្ជៈ បំរើទីលានកីឡា-អាងហែលទឹកនឹងការិយាល័យចុះឈ្មោះកក់កន្លែងកំសាន្ត ឬការិយាល័យដោះស្រាយបញ្ហាលុយកាក់សុទ្ធសឹងតែពួកអាស៊ីស្ទើរតែទាំងអស់តែយើងពុំបានជួបខ្មែរ លាវ ឬវៀតណាមទេ ៕





តទៅលេខក្រោយ








Linda Sopheap sou

# New Year, New Leadership for Angkor Dance Troupe.



by James Ostis

ក្រុមរបាំអង្គរមាននាយកប្រតិបត្តិថ្មី នាដើមឆ្នាំ២០១៤ នេះ គឺ លីនដា សូភាព ស៊ូ គឺជាកូនស្រីបង្កើតរបស់ស្ថានិកនាយកបេសកកម្ម ធីម ធូ ។ កញ្ញា លីនដា សូភាពស៊ូ មានតួនាទីថ្មីមែន ប៉ុន្តែមិនមែនថ្មីសម្រាប់សមាគមខ្លួនឡើយនាងធ្លាប់កាន់ជាប្រធានសមាគមរបាំអង្គរនេះចំនួន៤ឆ្នាំរួចមកហើយ ។ តំណែងជាប្រធានសមាគមបានត្រូវទទួលដោយ លីយ៉ាណា ឃូស៊ី ដែលពីមុនមានតួនាទីជាអនុប្រធានសមាគម ។

*សូមអានអត្ថបទ ដេម អស់ទីស ជាភាសាអង់គ្លេសជាបន្តទៀត ។*

With the new year comes new leadership for one of Lowell's oldest Cambodian cultural institutions. After four years as the president of the board of directors, Linda Sopheap Sou was named as the new executive director of Angkor Dance Troupe. In her new role, she will oversee much of the day-to-day programmatic elements of the organization. Lianna Kushi, who served as the vice president in 2013, takes over as the new president of the board, which is tasked with providing the overall planning and direction for the troupe.

Sou, the daughter of troupe founder and director of operations Tim Thou, has been involved with the group since its inception and is excited about the latest chapter of what has been a lifelong passion. "It is an honor to take on the role of executive director and to be a part of the team that will make sure our vision comes true."

Last May at the law offices of Gallagher & Cavanaugh, Angkor Dance Troupe convened a community discussion, "Visioning Angkor's Future," in which the organization laid out its short, medium, and long term plans.

That vision already includes a packed calendar for 2014. The Evolution of Cambodian Dance Film Series continues with on January 21, with a free screening of the Monkey Dance at the Lowell National Historical Park Visitors Center. On April 3, Angkor Dance Troupe will collaborate with UMass Lowell's Arts & Ideas and the World Music Ensemble for a major fundraising performance at the University's Durgin Hall. The troupe's annual recital will be held on June 7th where there will be a demonstration of the new annual examination process that will start for the class of 2015. Finally, in October, Angkor Dance Troupe will establish a permanent residency at the Merrimack Repertory Theater in the first year of a multi-year collaboration with the support of the Greater Lowell Community Foundation and Lowell Cultural Council. In addition to these new endeavors, the troupe will continue to provide its full schedule of weekly classes and regular performances at various festivals and cultural events throughout the year.

The training program and the MRT partnership were both goals outlined in the two-year plan at last year's visioning session. Longer-term goals in process include the establishment of a permanent Lowell Angkor Arts Academy and full-time touring company. With a passionate staff and board of directors, Angkor Dance Troupe has a leadership team in place truly dedicated to the realization of their vision. For more information on Angkor Dance Troupe, please visit www.angkordance.org or call (978) 275-1823.



"Left to Right: President Lianna Kushi, Executive Director Linda Sou, 1st Vice President Sochenda Uch, Chummeng Suon, Narin Sinuon, Michael Gallagher (event host), 2nd Vice President Sovanna Pouv, Operations Director Tim Thou, Treasurer Vyrik Eng, Clerk Linda Uch."



Lianna Kushi




**HELP WANTED ជ្រើសរើសបុគ្គលិក**

A busy Restaurant in Philadelphia
Seeking for a Chef to cook full time
Competitive salary.
ត្រូវការចុងភៅ ធ្វើការពេញម៉ោង
ប្រាក់ខែល្អ
ធ្វើការក្នុងភោជនីយដ្ឋាន សំបូរភ្ញៀវចេញចូល
នៅហ្វីឡាដែលហ្វៀ
Please call Jimmy for details.
sUmehA CImmI 215-688-1313

**BUSINESS FOR SALE**
**BEAUTY SALON with TANNING**

ប៊ីសនីស ត្រូវលក់ចេញឆាប់
កែសម្ផស្ស និង ថៃននីង (Tanning)
ហាងទំហំ 1,500 Sq.
151 Central St., Lowell, MA 01852
តម្លៃ $9,800
សូមទាក់ទង នីកូឡាស 978-454-7008
ថ្លៃជួលហាង និងទឹក ភ្លើង
( ប្រហែល 1000ដុល្លារ/1ខែ)
អាចចរចាតម្លៃបាន

Golden Video Shop Providence
មានលក់ថាសចម្រៀង និងខ្សែវីដេអូ-ខ្មែរ-ចិន-ថៃ (401)-808-9336
VM LAPTOPS CENTER
- VANNAK MOEUN (Manager)
មានជួសជុល-ទិញ និងលក់"ឡាប់តុប"គ្រប់យ៉ាង
**301 Reservoie Ave. Providence RI 02907**

**ប្រូវិជិនខ្មែរវីដេអូ**
មានជួលនិងលក់កុនចិន-ថៃ-ខ្មែរ-ឥណ្ឌាគ្រប់ប្រភេទមានចម្រៀងសម័យវីដេអូ ខារ៉ាអូខេថ្មីៗ
742 Potters Avenue
Providence, RI 02907 ទូរស័ព្ទ : **(401) 787 6663**

តមកពីទំព័រទី ១១

## គណបក្សសង្គ្រោះជាតិសង្ឃើញរក...

លទ្ធភាពប្តូរដៃថ្នាក់ដឹកនាំបានភ្លាមតែគណបក្សប្រជាជនកម្ពុជាក្បាលរឹងត្រូវការពេលវេលាខ្លះទៀត ដោយសង្ឃឹមថា នៅ៣-៤ឆ្នាំខាងមុខអណ្តូងប្រេងកាតនឹងបង្ហូរផលផ្តល់ធនធានមហាសាលដល់ពួកគេពេលនោះពុំអាចផ្តួលរំលំបានឡើយ ។ ការទាមទារយ៉ាងសង្ឃើញរបស់រលកបាតុករខ្មែរនេះ នឹងឈានទៅរកសម្រេចជោគជ័យឆាប់ៗពីព្រោះ អ្វីៗបានត្រូវគាំងដំណើរស្ទេញទៅហើយបើក្នុងសភាជាតិបន្តគ្មានការចូលរួមពីគណបក្សសង្គ្រោះជាតិទេនោះ នឹងបើប្រជាជាតិនៅតែស្ថិតនៅក្នុងរលករំជើបរជួលគ្មានឈប់យ៉ាងនេះ។ លោក ហ៊ុន សែន ប្រើបច្ចេកទេសសង្គ្រាមត្រជាក់លាក់ក្រចកតាំងពីមុនបោះឆ្នោត រហូតមកដល់ចុងឆ្នាំ២០១៣ ក៏បង្ខំចិត្តលាក្រចកបង្ហាញមុខមាត់ពិតឡើងវិញ នោះដើមឆ្នាំថ្មី ដើម្បីស្រោចស្រង់អំណាចដែលស្រកស្រុតពីដៃបាតុករអហឹង្សានឹងពីដៃគណបក្សប្រជាជនខ្លួនឯងដែលខ្វែងគំនិតផ្ទៃក្នុងយ៉ាងខ្លាំងពីរឿងចាញ់ឆ្នោតនេះ "ក្រាញតោងអំណាចរបស់ ហ៊ុន សែន តែអាចរលាយគណបក្សប្រជាជនទាំងមូល"ជាទំនាស់ដែល "គណបក្សប្រជាជនទាំងមូលចង់រក្សានិរន្តភាពជាមួយប្រជាជាតិឱ្យបានយូរអង្វែងអាចសុខចិត្តទម្លាក់ ហ៊ុន សែន ចោលតែម្នាក់ឯង ដើម្បីដំណោះស្រាយបច្ចុប្បន្ន"។ ហេតុនេះ ហើយបានជាគេឃើញភាពមិនប្រក្រតីនៃបទបញ្ជាការ ប្រើទាហ៊ានឆត្រយោងទៅបង្ក្រាបកម្មកររោងចក្រប្រើកម្លាំងសាលាក្រុងភ្នំពេញ ទៅរុះរើកន្លែងជួបជុំបាតុករអហឹង្សានៃទីលានប្រជាធិបតេយ្យដែលជាដៃ




ជើងផ្ទាល់របស់ ហ៊ុន សែន តែរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និយាយថា "រដ្ឋាភិបាលឥតមានបញ្ជាទេ។

**ដំណោះស្រាយ :** ឧបសគ្គធំដែលមិនអាចរំងាប់បាតុកម្មបាន គឺវត្តមាន ហ៊ុន សែន នៅជាប្រមុខរដ្ឋាភិបាលដែលបានយករាស្ត្រយកសភាជាតិយកព្រះមហាក្សត្រយករដ្ឋាភិបាល... ជាទ្រនាប់គូថរបស់ខ្លួនទៅហើយភាពក្រអឺតក្រទមទម្លាប់លួចគេទម្លាប់ បំរើបរទេសនឹងមិនផ្តល់អ្វីថ្មីដល់ការដោះស្រាយទំនាស់ទេ ដូច្នេះការប្តូរក្បាលម៉ាស៊ីនរបស់គណបក្សប្រជាជន ដើម្បីជៀសវាងការចរចា ទារយកតម្លៃខ្ពស់ពេក រហូតដល់រលាយទាំងអស់គ្នាគេអាចមើលឃើញចរន្ត ជា ស៊ីម អាចជាចម្លើយថ្មី សម្រាប់ដោះស្រាយវិបត្តិកម្ពុជាដែលនឹងផ្អែកទៅលើការគោរពដោយស្មោះត្រង់ដល់ភាគីប្រកួតប្រជែងនយោបាយជាធំ ។ លោក ស ខេង អាចជាជម្រើសនោះ ដើម្បីមកអារកាត់មិនឱ្យមានការ"បោះឆ្នោតសារជាថ្មី" ចរចាត្រឹមតែអនុញ្ញាតឱ្យ "រាប់សន្លឹកឆ្នោត" គោរពលទ្ធផលដែលនឹងចេញមកសារជាថ្មីដែលជាចំណុចទាំងគ្រប់ភាគីអាចយល់ព្រមបានដោយមិនឱ្យមានការបាក់មុខគណបក្សប្រជាជនដែលប្រជាប្រិយភាពបានត្រូវរំលាយដោយស្នាដៃ ហ៊ុន សែន អស់ទៅហើយ ។ ជាបន្ថមកទៀតគេអាចស្តារតួនាទីព្រះមហាក្សត្រខ្មែរ ដែលបានត្រូវ ហ៊ុន សែន ជាន់ឈ្លីដែរនោះ តែនៅមានការគោរពពីគណបក្សសង្គ្រោះជាតិនៅឡើយ ឱ្យព្រះអង្គធានាដល់សុវត្ថិភាពប្រជាជាតិរាប់ទាំងការលើកលែងទោស តាមការស្នើពីសមាជិកគណបក្សណាមួយដែលនឹងក្លាយជាបក្សប្រឆាំងបន្ទាប់ពីរាប់សន្លឹកឆ្នោតរួចមកផងដែរ ។

គំនិតនេះអាចអនុវត្តន៍ទៅបាន លុះត្រាណាតែគណបក្សប្រជាជនឈប់គិតថា "ប្រទេសកម្ពុជាជាជ័យភណ្ឌរបស់"ថ្ងៃ៧មករា"ហើយប្រគល់ប្រទេសកម្ពុជាឱ្យមកជាសម្បត្តប្រជាពលរដ្ឋខ្មែរទាំងមូលវិញ ទើបយកជ័យជំនះបានទាំងអស់គ្នា ៕






# ឆ្នាំថ្មីតើយើងប្រាថ្នាធ្វើអ្វីខ្លះ?



សង្វាត់វិលវិញខ្លួនឯងនៃផែនដីបាន ១ជុំក្នុង១ថ្ងៃ និងជុំវិញព្រះអាទិត្យបាន ១ជុំក្នុងឆ្នាំដែលជាសញ្ញាពីការវិវដ្តប្រែប្រួលទៅនៃថ្ងៃខែឆ្នាំ។

រយៈពេល១ឆ្នាំកន្លងទៅ គឺជាពេលវេលាមួយដែលបណ្តាជនម្នាក់ៗរមែងបានខិតខំប្រឹងប្រែងកែច្នៃលក្ខណៈស្ថានភាពជីវិតរបស់ខ្លួន ដោយប្តេជ្ញាតាំងចិត្តថា ក្នុង១ឆ្នាំនេះ ត្រូវតែបំពេញភារកិច្ចទៅតាមមុខនាទីមុខរបរដែលម្នាក់ៗបានជ្រើសយកមកប្រកបជារៀងរាល់ថ្ងៃ ដើម្បីបានកំរៃជាប្រាក់បៀវត្សជាប្រាក់ចំណេញ ឬជាប្រាក់រង្វាន់សំរាប់យកមកបំពេញការខ្វះខាតចិញ្ចឹមជីវិតខ្លួនឯង និងគ្រួសារព្រមទាំងកែច្នៃសុវត្ថិភាពគ្រួសារឱ្យកាន់តែប្រសើរឡើងៗមានន័យថា កិត្តិយសក្តី សេចក្តីថ្លៃថ្នូរក្តី សេចក្តីសុខសាន្តក្តី សុវត្ថិភាព និងសុភមង្គលក្នុងគ្រួសារក្តីបានកើតចេញមកពីការខិតខំប្រឹងប្រែងព្យាយាមស្វែងរកដោយខ្លួនឯងម្នាក់ៗ ទើបបានសម្រេចជោគជ័យក្នុងជីវិតជាពិតប្រាកដ។

បណ្តាប្រជាពលរដ្ឋស្ទើរតែ១00ភាគរយបានផ្តោតអារម្មណ៍របស់ខ្លួននៅក្នុងពេលបំណាច់ឆ្នាំចាស់ ហើយចាប់ផ្តើមចូលឆ្នាំថ្មីម្តងៗម្នាក់ៗតែងតែបានបញ្ចេញនូវប្រតិកម្មរៀងៗខ្លួន ទៅតាមការយល់ឃើញរបស់ខ្លួនមានខ្លះបានដណ្តឹងសួរគ្នាថា តើនៅក្នុងរយៈពេល១ឆ្នាំដែលបានកន្លងទៅនេះ យើងបានធ្វើអ្វី ខ្លះ?

**តើស្ថានភាពជីវិតរស់នៅដូចម្តេចខ្លះ?**
**តើបានសន្សំលុយទុកបានប៉ុន្មាន?**

តើមានកូនប្រុសកូនស្រីបានរៀនសូត្រដល់ថ្នាក់ណាខ្លះ និងចប់ការសិក្សាបានសម្រេចជោគជ័យប៉ុន្មាននាក់?

នេះជាសំណួរខ្លះ ដែលចង់ដឹងពីឆ្នាំចាស់កន្លងទៅ។

ចំណែកនៅពេលចូលឆ្នាំថ្មីដែលនឹងមានបន្តទៅទៀតរយៈពេលមួយឆ្នាំខាងមុខ ក៏មានសំណួររំលឹកគ្នាថា តើនៅក្នុងឆ្នាំថ្មីនេះ យើងអាចមានគម្រោងធ្វើអ្វីជាថ្មីតទៅទៀត ?

តើឆ្នាំថ្មីនឹងអាចនាំយើងឱ្យទៅតាមសេចក្តីប៉ងប្រាថ្នារបស់យើងបានឬទេ ? ឱ្យត្រូវទៅតាមពាក្យមួយឃ្លាដែលនិយាយថា ឆ្នាំថ្មីគឺជាគំនិតថ្មីជាចិត្តថ្មីមានគម្រោងផែនការថ្មី ហើយត្រូវខិតខំប្រព្រឹត្តធ្វើអ្វីៗបង្ហាញជាលក្ខណៈថ្មីទាំងអស់។

ឆ្នាំដែលកន្លងហួសទៅជាឆ្នាំចាស់តែងតែបង្កើតអាយុមនុស្សម្នាក់ៗឱ្យកាន់តែច្រើនឡើងប៉ុន្តែវាកាន់តែកាត់បន្ថយអាយុឱ្យមនុស្សកាន់តែខិតទៅជិតដល់កំណត់លាចាកលោកលោកនេះទៅវិញ ។ ដូច្នេះមនុស្សម្នាក់ៗតែងតែមានសតិអារម្មណ៍ខុសគ្នា ខ្លះយល់ថា ចូលឆ្នាំថ្មីយើងសប្បាយរីករាយណាស់ ដោយសារតែបានទទួលជោគជ័យជាច្រើនពីឆ្នាំចាស់មក ហើយមុខជានឹងបានទទួលជោគជ័យថ្មីជាច្រើនទៀត នៅក្នុងឆ្នាំថ្មីខាងមុខនេះ។

ចំណែកខ្លះយល់ថា ចូលឆ្នាំថ្មីគឺបានធ្វើឱ្យខ្លួនកាន់តែចាស់បន្តិចម្តងៗកម្លាំងកាន់តែអន់ខ្សោយបន្តិចម្តងៗសុខភាពកាន់តែទ្រុឌទ្រោមបន្តិចម្តងៗ ដែលសន្និដ្ឋានបានថា អាយុជីវិតរបស់ខ្លួនបានខិតទៅជីវិតរបស់ខ្លួនបានខិតទៅជិតដល់ថ្ងៃមរណភាពណាស់ហើយដែរ ប៉ុន្តែទោះបីជាយ៉ាងនេះក៏ដោយ ក៏វាជាការវិវឌ្ឍទៅនៃជីវិតរបស់មនុស្សសត្វទូរទៅនៅក្នុងលោកដែលចាត់ទុកថា ជាសភាវធម៌ ធម្មតារបស់ មនុស្ស និងសត្វ។

ដោយសារតែនេះជាសភាពធម៌ធម្មជាតិ ទើបសារព័ត៌មានខ្មែរប៉ុស្តិ៍ដែលជាអង្គការផ្សព្វផ្សាយព័ត៌មានជូនដល់ចំណេះវិជ្ជាចេះដឹងទូទៅជួយផ្តល់ដំណោះស្រាយបញ្ហាផ្សេងៗក្នុងសង្គមជួយពន្យល់ណែនាំបណ្តាជន និងសង្គមឱ្យបានស្វែងរកឃើញសេចក្តីសុខសាន្ត សុភមង្គលវិបុរលសុខ សុវត្ថិភាព និងយុត្តិធម៌នៅក្នុងសង្គម ។ ដូច្នេះនៅក្នុងរយៈពេល១ឆ្នាំ២០១៣បានកន្លងទៅខ្មែរប៉ុស្តិ៍បានបំពេញភារកិច្ចមួយ ដ៏មមាញឹក ស្វិតស្វាញ អំណត់អត់ធន់ ទោះបីមានការជួបប្រទះនឹងឧបសគ្គខ្វះខាតខាងផ្នែកមធ្យោបាយជាសម្ភារៈ ឬថវិកាក្តីយ៉ាងណាក៏ដោយ ក៏ក្រុមប្រឹក្សាភិបាលខ្មែរប៉ុស្តិ៍រួមជាមួយលោកនាយកបានខិតខំដោយអស់ពីសមត្ថភាពដើម្បីបំរើដល់សហគមន៍ជាតិខ្មែរ និងសង្គមគ្រួសារខ្មែរ ដោយពេញទំហឹង និងស្មោះស្ម័គ្របំផុត ដែលជាសក្ខីភាពរបស់យើងខ្ញុំទាំងអស់គ្នាជាអ្នកសរសេរព័ត៌មាន។

នៅក្នុងឱកាសចូលឆ្នាំថ្មី២០១៤នេះ សូមបន់ស្រន់បួងសួងដល់គុណបុណ្យព្រះគ្រប់ព្រះអង្គ និងទេវតារក្សាឆ្នាំថ្មីសូមព្រះអង្គប្រទាននូវព្រះពរជ័យ សិរីមង្គល វិបុលសុខ មហាប្រសើរគ្រប់ប្រការមានសុខភាពល្អ និងមានអាយុយឺនយូរគ្រប់ៗគ្នាក្នុងឆ្នាំថ្មីនេះ និងក្នុងឆ្នាំជាបន្តៗទៅខាងមុខទៀតកុំបីឃ្លាងឃ្លាតឡើយ។

ជាពិសេសខ្មែរប៉ុស្តិ៍សូមថ្លែងអំណរគុណជាអតិបរមាដល់អស់លោកអ្នកជាអតិថិជនប្រកបមុខរបររកស៊ីទទួលជាពាណិជ្ជករគ្រប់វិស័យដែល

បានជួយផ្គត់ផ្គង់ឧបត្ថម្ភផ្នែកថវិកាបណ្តាលឱ្យខ្មែរប៉ុស្តិ៍មានជីវិតរស់រានដ៏ល្អប្រសើររហូតមកដល់ថ្ងៃនេះ សូមប្រសិទ្ធិពរជ័យគ្រប់ប្រការរមែងកើតមានដល់អស់លោកអ្នកទាំងនោះជានិច្ចនិរន្តរៀងទៅដែរ។ **ម៉ម យីន**


# មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE
978-596-1111

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

**អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?**

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងជានាទូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

**ទីតាំងនៃមណ្ឌល**

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។



**មណ្ឌលផ្តល់សេវាដល់មនុស្សចាស់**

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម (ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ)
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

**Our Services**

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

# ឆ្នាំថ្មីនយោបាយថ្មីនៅឡូវែល



Richard Howe Jr.

ថ្ងៃទី៣ មករា គឺជាថ្ងៃដែលគណក្រុមប្រឹក្សាក្រុងឡូវែលថ្មីបានចូលកាន់តំណែងរបស់ខ្លួនអ្នកដែលថ្មីស្រឡាងគឺ ដន រ៉ត -ជីម មីលីណាសូ - ប៊ិល សាមារ៉ា - និង កូរី ប៊ិឡនជ័រ អ្នកដែលបានមិនបានជាប់ឆ្នោតម្ដងទៀតមាន បាទ្រិក ម័រហ្វិ ចៅហ្វាយក្រុងចាស់មិនឈរឈ្មោះទៀតទេ និង ម៉ា ទី លរី - វ៉ាស្នា នួន -ជោ មិនដងតា ហើយនិងអ្នកជាប់ឆ្នោតម្ដងទៀត គឺ រីតា មឺស្យេ- រ៉ូនី អេលីយ៉ុត - អេដ គេណឺឌី - ប៊ិល ម៉ាទីន និង ជន លី ។ រ៉ត នី អេលីយ៉ុត -បានត្រូវតែងតាំងជាចៅហ្វាយក្រុងក្នុងកិច្ចប្រជុំថ្ងៃទី៦ មករា កន្លងទៅនេះ ។ តែដំណឹងដ៏គួរឱ្យភ្ញាក់ផ្អើលមួយធ្លាក់មក គឺការលាលែងពីតំណែងនាយកការិយាល័យគ្រប់គ្រងក្រុងឡូវែលរបស់ ប៊ើនី លីន មុនចប់អាណត្តិរបស់ខ្លួន ។

គណក្រុមប្រឹក្សាសាលាក្រុងបានថ្លែងពីគម្រោងដ៏ធំក្នុងអាណត្តិ២ឆ្នាំរបស់ខ្លួន គឺការប្រយុទ្ធប្រឆាំងនិងអំពើហឹង្សា និងសន្តិសុខសាធារណៈ ។

សូមអញ្ជើញអានសេចក្ដីរាយការណ៍ពិស្តារជាភាសាអង់គ្លេសរបស់ រីឆាត ហាវ

## Lowell politics in 2013

*By Richard P. Howe Jr.*

The 2014 political year in Lowell started with the shocking announcement by City Manager Bernie Lynch that he would resign his office on March 10, 2014. The city council will now begin the task of selecting his replacement. Although the City Manager's resignation occurred in 2014, it was events in 2013 that laid the groundwork for his departure so let us now review some of the important political events in Lowell from the past year.

In November, four new city councilors were elected. They are Dan Rourke, Jim Milinazzo, Bill Samaras and Corey Belanger. Those who are leaving the council are Mayor Patrick Murphy who did not seek reelection and Marty Lorrey, Vesna Nuon and Joe Mendonca who all failed to win reelection. Returning to the council will be Rita Mercier, Rodney Elliott, Ed Kennedy, Bill Martin and John Leahy. (At the January 6, 2014 Inauguration Ceremony, the new council selected Rodney Elliott to be Mayor for the next two years).

A big issue in the city council election and throughout the community was violence and public safety. The police assured residents that statistically there was less crime in 2013 than there was in 2012, many residents felt differently. Much of the violence involved shootings in the lower Highlands and Centralville but downtown also became the focus of the public safety debate as the city searched for ways to hold downtown bars accountable for the behavior of unruly customers.

There were also leadership changes for the Lowell Public Schools. Steve Gendron, who served on the city council in the 1990s and on the planning board for the past few years, decided to run for school committee and won a seat. With just seven candidates for six seats there was only one who lost. That was Robert Gignac who had just finished his first term on the school committee. In other school news, Brian Martin, former city councilor, mayor, city manager, and Congressional district director, was hired as the new Lowell High School headmaster.

There were other personal changes in the city and in nearby communities. Chief Financial Officer Tom Moses recently left Lowell when he was hired to be town manager in Hudson. He has not yet been replaced. Ken Lavallee retired as superintendent of police in March. He was immediately replaced on an interim basis by Deputy Superintendent Deborah Freidl and in November, the city manager choose veteran captain Bill Taylor to be the new superintendent.

The November city council election was not the only big election in 2013. In June, there was a special election to fill the U.S. Senate seat vacated when John Kerry (who once lived in Lowell) was named Secretary of State. That election was won by long-time Democratic Congressman Ed Markey who defeated Republican nominee Gabriel Gomez statewide and also in Lowell, 58% to 42%.

Perhaps the best new in 2013 was the continued growth of UMass Lowell was a big story in 2013. There are new buildings such as the Health and Social Science Building and the new parking garage on South Campus and the University Crossing student center at Pawtucket and Merrimack Streets is going up quickly. UMass also received much national attention for the improving quality of its faculty and students which benefits the entire community






# ១១មករា បាតុកម្មនៅត្រូការ៉ូ ប៉ារីស ថ្កោលទោស ហ៊ុន សែន ជនផ្តាច់ការ ជាឃាតករសម្លាប់មនុស្ស

១១មករា បាតុកម្មនៅត្រូការ៉ូ ប៉ារីស ថ្កោលទោស ហ៊ុន សែន ជនផ្តាច់ការ ជាឃាតករសម្លាប់មនុស្ស

នៅថ្ងៃទី១១មករា មានបាតុករខ្មែរជិត១ពាន់នាក់នៅអឺរ៉ុបបានមកជួបជុំ ធ្វើបាតុកម្មបញ្ចេញកំហឹងឆ្លើយតបទៅរបប ហ៊ុន សែន ជនផ្តាច់ការ ដែលបានបង្ក្រាបមហាបាតុកម្មអហិង្សានៅភ្នំពេញកាលពីថ្ងៃទី២-៣-៤មករា បណ្តាលមានមនុស្សស្លាប់ របួស និង ចាប់ឃុំឃាំងដាក់គុកជាច្រើន។ SAKOU Samoth




















តមកពីទំព័រទី ១ វាចារ លោក វាសនា នួន នាឱកាសដាច់ឆ្នាំ...

"ខោងទីទីដលែដលសេខេជាមួយគ្នា យើងជាក្រុមប្រឹក្សា ឬក៏ជាខ្មែរមួយរូបហ្នឹងមិនមែនចេះតែទៅដោះស្រាយនៅទីណាដែលគេមិនហៅរកនោះទេ ឥឡូវនេះគេដោះស្រាយគ្នានៅតុលាការ បើដោះស្រាយកើតកាលពី៣ឆ្នាំមុនតុលាការគេឱ្យរូបមន្តមកហើយ តែយើងធ្វើមិនកើតញ!

**ខ្មែរផុសៈ** តើទៅអនាគត់នឹងមានដំណោះស្រាយយ៉ាងម៉េចរួច ។

**វាស្នា នួន :** ដំណោះស្រាយបែបតុលាការនោះ ហាក់ដូចជាសមរមហើយ តែគណកម្មការនោះមានលើមានក្រោមនៅឡើយ ការវិវត្តន៍មកទល់ថ្ងៃនេះឮថា បងប្អូនវត្តក្រោមនឹងបងប្អូនវត្តលើរួមទាំងក្រុមប្រឹក្សាវប្បធម៌កចចដែលដើតួរជាក្រុមកណ្តាលនោះ មានបំណងបង្រួបបង្រួមវត្តឱ្យទៅតែមួយដែរហើយ ប្រសិនបើបំណងនេះពិតប្រាកដមែន ខ្ញុំនិយាយម្តងទៀតថា "បំណងពិតប្រាកដ" នៅមានរូបមន្តចុងក្រោយមួយទៀតដែលសមរមដែរ ដូចជាថា ថ្ងៃនេះគណកម្មការទាំងអស់សម្រេចយកថ្ងៃណាមួយសម្រាប់ឱ្យពលរដ្ឋមកបោះឆ្នោតរើសគណកម្មការវត្តថ្មីមួយឧទាហរណ៍ថាយកថ្ងៃ១៥កុម្ភៈ ២០១៤ ជាថ្ងៃបោះឆ្នោតយើងទុកកចចដោយឡែក ហើយថ្ងៃនេះយើងលាលែងទាំងអស់គ្នាពីដំណែងក្នុងគណកម្មាការវត្តទាំងលើទាំងក្រោម ហើយចុះឈ្មោះដោយសេរីជាបេក្ខជនបំរើក្នុងគណកម្មការវត្តត្រៃរតនារាមឱ្យពលរដ្ឋគេបោះឆ្នោតឱ្យនរណាក៏ឈរឈ្មោះបានដែរ ពេលនោះអ្នកជាប់ឆ្នោតនឹងក្លាយជាគណកម្មការវត្តតែមួយគ្មានពីរទៀតទេ ។




**ខ្មែរផុសៈ** មានយោបល់ជាច្រើននិយាយថាឱ្យគណកម្មការចាស់ទាំង២រំលាយខ្លួន ហើយមិនឱ្យឈរឈ្មោះវិញទេ តើលោកយល់យ៉ាងណាដែរ?

**វាស្នា នួន :** បើខ្ញុំយល់ថា អ្នកណាឈរក៏បានដែរ ខ្ញុំគ្មានយល់ទាស់ទេ ពួកគាត់ទាំងអស់នោះក៏ជាសកម្មជនរបស់វត្តដែរ ហើយគួរតែឱ្យគាត់ឈរឈ្មោះបានផង តែគណកម្មការទាំង២លាលែងទាំងអស់គ្នា ឈប់មានលើមានក្រោមឱ្យបាន២ខែមុន ដើម្បីប្រាប់ឱ្យប្រជាពលរដ្ឋបានដឹង ហើយឱ្យមកបោះឆ្នោត ។

**ខ្មែរផុស :** បើឱ្យគណកម្មការទាំងពីរលាលែងមុន២ខែ តើក្នុង២ខែនោះមាននរណាគ្រប់គ្រងវត្ត?

**វាស្នា នួន :** បើចង់លាលែងភ្លាមបោះឆ្នោតភ្លាមក៏បានដែរ តែក្រែងគ្មានពេលគ្រប់គ្រាន់សម្រាប់ប្រាប់បងប្អូនឱ្យមកបោះឆ្នោត ! បើទុកពេលយូរបន្តិចក៏បានដែរ ដូច្នេះត្រូវបង្កើត "អាត់ហុក"គណកម្មការបណ្តោះអាសន្នមួយទៅសម្រាប់គ្រប់គ្រងវត្តនៅអន្តរកាលនោះទៅ! តែត្រូវលាលែងកុំឱ្យមានវត្តលើវត្តក្រោមជាមុនតែមកទល់ពេលនេះខ្ញុំឥតឮថាមានការលាលែងជាមុននោះ នៅឡើយទេ!

**ខ្មែរផុសៈ** ឥឡូវនេះវត្តលើចង់ធ្វើការជួសជុលវត្តផ្នែកខាងលើចែកផ្តាច់ "កុងទ័រ"ភ្លើងតែម្នាក់ឯង នេះមិនមែនជាបំណងបំបែកវត្តទេឬ បើការជួសជុលមិនធ្វើរួមគ្នាទេនោះ?

**វាស្នា នួន :** បើចិត្តយើងចង់បានវត្តតែមួយមែននោះ បើវត្តទាំងសងខាងនោះព្រមព្រាងគ្នាថារំលាយគណកម្មការទាំង២ចោលហើយនោះការបោះឆ្នោតនឹងបានត្រូវកំណត់ឱ្យបងប្អូនដឹងជាមុនឱ្យបានយូរគណៈកម្មការ "អាត់ហុក"បង្កើតឡើងសម្រាប់គ្រប់គ្រងអន្តរកាលពេលនោះ យើងសម្រេចគ្នាទៅថាធ្វើអ្វីខ្លះធនធានវត្តត្រូវដាក់បញ្ចូលគ្នាសម្រាប់ចំណាយតែមួយគ្មានលើគ្មានក្រោម ព្រោះជាលុយបងប្អូនតែទាំងអស់ហ្នឹង! អារឿងពីមុនមកហ្នឹងជីកកប់វាទៅ! បើទុកវាតទៅទៀត ឥតមានផ្លូវដើរទេ... មិនត្រឹមតែប៉ុណ្ណឹងកាសែត "ឡូសាន់"ហ្នឹងកាសែត"ខ្មែរផុស"របស់បងហ្នឹងលើកមកបង្ហាញសង្គមធំហ្នឹង ធ្វើឱ្យគេឃើញគ្រប់គ្នាថា សង្គមខ្មែរយើងហ្នឹងឈ្លោះកាប់ចាក់គ្នាមិនចេះឈប់ ឥឡូវនេះឱ្យតែមានទំនាស់កាសែតបងហ្នឹង កាសែត"ឡូសាន់"ហ្នឹងចុះផ្សាយសួរថាតើសង្គមធំហ្នឹងគេយល់យ៉ាងណា ចំពោះយើង? គេសប្បាយចិត្តណាស់តិចថាគេមកផ្តល់ការដោះស្រាយអ្វីឱ្យចេញជាលទ្ធផលល្អអីនោះ! គឺពេលដែលយើងកំពុងកាប់ចាក់គ្នានោះហើយដែលថាកម្លាំងខ្មែរយើងបែកជាច្រើនបំណែកអស់រលីងនោះ ។

*(លេខក្រោយយើងនឹងបន្តវាចាលោកវាស្នា នួន ស្តីពីសេដ្ឋកិច្ចសហគមន៍ខ្មែរ)*

# Lowell City Manager Lynch to resign

បើ នី លីន ជានាយកការិយាល័យសាលាក្រុងឡូវែលតាំងពី៧ឆ្នាំកន្លះមកហើយ ។ គឺជានាយកដែលមានប្រវត្តិការងារនេះយូរជាងគេបង្អស់នៅទីក្រុងឡូវែលលោកបានពង្រីកស្ថានភាពហិរញ្ញវត្ថុឱ្យមាំទាំឡើងវិញ បន្ទាប់ពីព្យាបាលឱនភាពបន្តពីពេលមុនរួចមក ។ លោកនិងបញ្ចប់ការងារដ៏សំខាន់នេះនៅថ្ងៃទី១០ មិនា ២០១៤ ខាងមុខនេះហើយ ។



City Manager, Bernard Lynch

The new city council will not have to wait long for its first major decision. At the end of the January 6th council meeting, the first of the new term, City Manager Bernard Lynch announced his intention to resign from his office effective March 10th, 2014. Lynch, who was first hired in July 2006, had less than a year remaining on his contract and a major question mark of the new council was whether or not his deal would be extended. But Lynch had other plans, and in keeping with the terms of his contract, gave the council two months notice of his plans to exit 375 Merrimack St.

Lynch's 7 ½ year stint as manager makes him one of the longest serving city managers in Lowell's history. During his time in office, the city was able to drastically strengthen its financial well-being after facing large deficits and being placed on a Massachusetts Department of Revenue watch list during the previous administration. Lynch also made efforts to reach out to the diverse communities of Lowell through board appointments and supported various innovative municipal government reforms.




ហាងខ្មែរជួសជុលរថយន្ត

បើចង់ឱ្យរថយន្តលោកអ្នករត់បានល្អ សូមអញ្ជើញ

Rathe´s Auto Service

State and Emission Inspaction General Repairs and Maintenance

MON-SAT, 8:30AM-5:30PM
SUN. EMERGENCY ONLY




- ជាងមានបទពិសោធន៍ជាយូរឆ្នាំ -ជួសជុលរថយន្តគ្រប់ប្រភេទ
- មានដូរប្រេង ដូរហ្វ្រាំង ដូរកង់ និងករណីជាច្រើនទៀត ។
- មានត្រួតពិនិត្យគ្រឿងម៉ាស៊ីន DIAGNOSTICS ដោយឥតគិតថ្លៃ
- មានចុះថ្លៃពិសេស ចាប់ពីខែកុម្ភៈ ២០០៨ ទៅ : - ដូរប្រេងក៏រិត ៥ ក្វាត $22
- INSPECTIONS រថយន្តឆ្នាំ 96 up $49.99+ តាក់ -មានជូនប័ណ្ណពិសេសសំរាប់ដូរប្រេងចុះថ្លៃពាក់កណ្ដាល នៅពេលយកមកជួសជុលអស់តម្លៃ $150.
- តម្លៃជួសជុលទូទៅ សមរម្យ ដោយទាបជាងហាងជួសជុលផ្សេងៗទៀត ។
- ប្តេជាចិត្តធ្វើជូនដោយហ្មត់ចត់ គុណភាពខ្ពស់ មិនឱ្យខុសបំណងលោកអ្នកឡើយ។ ពិសេស ជួយទៅពិនិត្យដល់កន្លែងនូវរថយន្តណាដែលខូច STARTER ឬ ធុងអាគុយអស់ភ្លើងដោយឥតគិតថ្លៃ ។ *សូមអរគុណ !*

5105 N.2ND ST., PHILADELPHIA, PA 19120. TEL : (215) 329-2418
Fax : (215) 329-2419. Rath CELL : (215) 431-6376

AccuCare

កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

Homecare Agency
Group Adult Foster Care Program (GAFC)
MassHealth

ជាសេវាមានគុណភាពខ្ពស់ និងទុកចិត្តបាន
បុគ្គលិកមានសណ្ដានចិត្តល្អ និងធ្វើការតាមវិជ្ជាជីវៈ
អ្នកគ្រប់គ្រង និងបុគ្គលិកនិយាយភាសាខ្មែរ



*Compassionate Care & Reliable Professional & Cultural Sensitive Management & Staffs speak Khmer*

*កម្មវិធី Group Adult Foster Care (GAFC) គឺជាដំណោះស្រាយល្អបំផុតសំរាប់ចាស់ៗ ខ្មែរយើង ដែលមានប ញ្ហារាំរ៉ៃផ្នែកសុខភាព ឬជរាហើយមិនចង់ ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុមគ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ យើងអាចជួយអោយជីវិតលោកអ្នកកាន់តែប្រសើរឡើង តាមរយៈការផ្ដល់នូវសេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្ដង ។*

*Accucare Homecare Agency is the perfect solution for seniors and others who are not ready to leave their home for an institutional setting or live with reltives because of illness or chronic conditions. We improve your life by providing one-on-one compassionate senior care in the comfort of your own home.*

*ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :*

*To be eligibled for GAFC you must:*

*-រស់នៅផ្ទះរដ្ឋ (live in subsidized or public housing)*
*-អាយុ ២២ ឆ្នាំឡើងទៅ (age 22 years and older)*
*-មាសប៉ៃហ៊ែលស្ទង់ដា (eligible for Masshealth Standard)*
*-ត្រូវការជំនួយក្នុងការរស់នៅប្រចាំថ្ងៃយ៉ាងហោចណាស់មួយដូចជា មុជទឹក ស្លៀក-ពាក់ ពេលប្រើបន្ទប់ទឹក ចំអិនអាហារ ឬ ពេលដើរ (need daily assistance with one or more personal care tasks such as bathing, dressing, toileting, meal preparation and/or moving)*
*-មានការអនុញ្ញាតពីគ្រូពេទ្យផ្ទាល់ខ្លួនអក (have physician statement of your condition)*
*-ត្រូវបានវាយតំលៃផ្នែកសុខភាព និងការអនុម័តយល់ព្រមពីកម្មវិធី (be screened and approved for the program )*

*ផលប្រយោជន៍ទទួលបាន :*

*Benefits you will get:*

*-ការថែទាំផ្ទាល់ខ្លួនមួយទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ (personal care service in your home, up to one hour of service each day)*
*-ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក (Medication Managemant)*
*-ផែនការថែរទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ (an individual care plan developed by a registered nurse and case manager)*
*-វាយតំលៃលើសេចក្ដីត្រូវការជាប្រចាំជាបន្តបន្ទាប់ (ongoing monitoring of needs)*
*-សមាជិកអាចទាក់ទងមក ២៤ម៉ោង (24-hour access to services)*

**ត្រូវការជ្រើសរើសបុគ្គលិកធ្វើការ PCA/ HHA needed for Lowell, Lynn, Revere, and Boston**

ដើម្បីចុះឈ្មោះសូមទាក់ទងមក
To register, please contact:



អ៊ុក តុលាយុទ្ធ ឡូវែល
Tolayuth Ok: Lowell
Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852



ពិន ឆាវ៉ាន់ លីន រីវៀរ បូស្តុន
Chhavan Pin: Lynn, Revere, Boston
Tel:(617)783-7177, Fax: (617) 783-7188
Office: 214 Lincoln St., Suite 200. Allston, MA 02134

# ជោគជតារាសីលោកអ្នក
## ទាំង១២ប្រចាំឆ្នាំរោង

### ឆ្នាំជូត

លោកអ្នកគួរប្រុងប្រយ័ត្នចំពោះការនិយាយស្តីបន្តិច ពីព្រោះអាចនឹងមានគូសត្រូវចាំចាប់ទោសកំហុសមួលបង្កាច់បង្ខូចកេរ្តិ៍ឈ្មោះរបស់លោកអ្នកឱ្យប្រែក្លាយទៅជាស្មុយអសោចិ៍ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញមានក្រុមមនុស្ស តាមឈ្នានីសច្រើន ដូចច្នេះត្រូវប្រយ័ត្នបន្តិចចៀសវាងការបរាជ័យ ។ រីឯបញ្ហាស្នេហាមានភាពចម្រូងចម្រាសដាក់គ្នាបន្តិចបន្តួច ៕

### ឆ្នាំឆ្លូវ

នៅក្នុងរយៈពេលនេះ លោកអ្នកទទួលលាភសក្ការៈពីសាច់ញាតិបងប្អូនដែលជិតស្និទ្ធ ។ ក្រៅពីនោះក៏នៅទទួលបានដំណឹងល្អដែលមានប្រយោជន៍ដល់ជាតិ និងការងាររបស់លោកអ្នកតទៅអនាគតទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញផលកម្រៃទទួលបានកាក់កបគ្រាន់បើតែហាមកុំជួញដូរផ្លូវឆ្ងាញប្រយ័ត្នមានបញ្ហាដល់ខ្លួន ។ រីឯបញ្ហាស្នេហាគូស្នេហ៍អាចមានការរកាំរកូសគ្នាខ្លះ ប៉ុន្តែមិនធ្ងន់ធ្ងរនោះទេ ៕

### ឆ្នាំខាល

ក្នុងរយៈពេលនេះលោកអ្នកជួបនឹងបញ្ហាខាងផ្លូវចិត្តមិនសូវជាសប្បាយរីករាយប៉ុន្មាននោះទេ តែប្រសិនបើចង់ទទួលផលពីការងារនោះ ចូរធ្វើចិត្តឱ្យត្រជាក់ទើបបានសម្រេចដូចបំណង ។ បើជាអ្នកប្រកបរបររកស៊ីជួញដូរវិញ គឺមានការប្រទាំងប្រទើសជាមួយអ្នកមានមុខរបរដូចគ្នា ដូច្នេះគួរបើកចិត្តឱ្យទូលាយ ។ រីឯបញ្ហាស្នេហាមានការកាំចិត្ត ព្រោះតែម្នាក់ៗចង់ចាញ់ឈ្នះគ្នានោះឯង ៕

### ឆ្នាំថោះ

លោកអ្នកអាចនឹងមានអារម្មណ៍ច្របូកច្របល់បន្តិចនៅក្នុងរយៈពេលនេះ ព្រោះកិច្ចការដែលថា នឹងទទួលបានផលល្អនោះវាអាចមានការប្រែប្រួលដោយសារតែមានការរំខានពីអ្នកដទៃ ។ បើចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចរកផលកម្រៃគ្រាន់ បើគួរជាទីគាប់ប្រសើរជាងមុន ។ រីឯបញ្ហាស្នេហា ពុំមានផលរមាស់អ្វីនោះឡើយ ៕

### ឆ្នាំរោង

រាល់ការបំពេញការងាររបស់លោកអ្នកក្នុងរយៈពេលនេះសុទ្ធតែផ្តល់នូវអត្ថ-ប្រយោជន៍ គួរឱ្យជាទីពេញចិត្តទាំងអស់ គ្មានអ្វីមករាំងស្ទះឡើយ ហើយជាងនេះទៀត នោះគម្រោងការដែលបានត្រៀមទុកជាយូរមក ហើយក៏នឹងបានសម្រេចផងដែរ ។ បើជាអាជីវកររកស៊ីវិញ មានការរីកចម្រើនលូតលាស់ទៅមុខជាលំដាប់ ។ រីឯបញ្ហាគូស្នេហ៍ច្រើនយល់ចិត្តគ្នា និងនឹករលឹកគ្នា បើនៅឆ្ងាយ ៕

### ឆ្នាំម្សាញ់

រាល់ការស្មុគស្មាញដែលធ្លាប់កើតមានលើលោកអ្នកក្នុងពេលនេះ នឹងត្រូវអហោសិកម្មទាំងអស់ ហើយទ្រព្យដែលរបូតចេញពីដៃទៅនឹងវិលត្រឡប់មកវិញយ៉ាងគ្រប់គ្រាន់ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ ត្រូវគិតគូរឱ្យបានច្បាស់លាស់មុននឹងដាក់ទុនថ្មី ទើបមិនខាតបង់រាល់ការចំណាយទាំងនោះ ។ រីឯបញ្ហាស្នេហាត្រូវចេះពូនជ្រោយចំណងស្នេហាដោយមានភាពផ្អែមល្ហែមទើបជាការប្រសើរ ៕

### ឆ្នាំមមី

រាល់កិច្ចការដែលលោកអ្នកប៉ងប្រាថ្នាជាយូរមក ហើយនោះក្នុងរយៈពេលនេះ គឺបានសមដូចបំណង ហើយគ្មានអ្វីមករារាំងនោះទេ ហើយរាល់ការប៉ងយាយីពីមនុស្សដែលមានបំណងមិនល្អមកលើលោកអ្នកនោះក៏មិនបានសម្រេចដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញអាចពង្រីកអាជីវកម្មឱ្យធំបន្ថែមទៀតបាន ។ ឯបញ្ហាស្នេហាគូស្វាមីភរិយាមានភាពសុខដុមរមនាគ្មានផលរមាស់អ្វីឡើយ ៕

### ឆ្នាំមមែ

រាល់ការបំពេញការងារទាំងឡាយលោកអ្នកមិនមានបញ្ហាអ្វីចោទនោះទេ ប៉ុន្តែក្នុងនោះ សូមប្រយ័ត្នកុំយកអាសាមនុស្សសម្បុរសឱ្យសោះ ព្រោះនាំឱ្យកើតរឿងសៅហ្មងទៅថ្ងៃក្រោយ ។ សម្រាប់អ្នកប្រកបមុខរបររកស៊ីជួញដូរវិញ អាចសន្សំទុកបានខ្លះ ។ រីឯបញ្ហាស្នេហាចូរកុំយកភាពមានះចង់ចាញ់ឈ្នះប្រយ័ត្នកើតមានជម្លោះវិវាទឈានដល់ការប្រេះស្រាំ ៕

### ឆ្នាំវក

រាល់កិច្ចការសព្វបែបយ៉ាងលោកអ្នកអាចជួបនឹងបញ្ហាខ្លះៗ នាគ្រាដំបូង ប៉ុន្តែក្រោយមកមិនមានអ្វីជាឧបសគ្គរារាំងទៀតឡើយ ។ ចំពោះអ្នកប្រកបមុខរបររកស៊ីជួញដូរវិញ មានការទិញចូលលក់ចេញគ្រាន់បើ អាចរកផលកម្រៃត្រឡប់មកផ្ទះវិញយ៉ាងត្រជាក់ចិត្ត ។ រីឯបញ្ហាស្នេហាមានភាពផ្អែមល្ហែម និងស្រស់ស្រាយប្រៀបដូចត្រីក្នុងទឹកនារដូវខែវស្សាដូច្នេះដែរ ៕

### ឆ្នាំរកា

លោកអ្នកមានភ័ព្វសំណាងល្អក្នុងការងារទទួលរឿងឡើងតួនាទី ឬប្រាក់បៀវត្សរ៍បន្ថែម ។ ជាងនេះទៀតនោះ ប្រសិនបើចង់ពឹងពាក់អ្នកមានយសស័ក្តិខ្ពង់ខ្ពស់ក្នុងរឿងអ្វីមួយនឹងបាន ដូចបំណងផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ អាចរកប្រាក់ចំណូលចិញ្ចឹមគ្រួសារបានដោយស្រួលទេ មិនមានអ្វីមករាំងស្ទះឡើយ ។ រីឯបញ្ហាស្នេហាគូស្នេហ៍រមែងចេះអត់ឱនឱ្យគ្នា ៕

### ឆ្នាំច

អាចពោលបានថា លោកអ្នកមានសេចក្តីសុខក្នុងជីវិត និងការងារ ព្រោះវិបត្តិ និងភាពស្មុគស្មាញដែលមានកន្លងមកក៏បានធូរស្រាលឡើងវិញមួយកម្រិតផងដែរ ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ ទោះបីជាចេញទៅជួញដូរ នៅទីណាក្តីគួរចៀសវាងការដាក់ទុនថ្មី ព្រោះអាចនាំឱ្យខាតបង់ ។ រីឯបញ្ហាស្នេហាគូស្នេហ៍ច្រើនប្រចណ្ឌខុសរឿង ៕

### ឆ្នាំកុរ

លោកអ្នកនឹងទទួលបាននូវលាភសក្ការៈពីភាគហ៊ុនរកស៊ី និងមិត្តរួមការងារយ៉ាងច្រើនគួរឱ្យពេញចិត្ត ។ លើសពីនេះទៅទៀតគម្រោងការដែលបានត្រៀមទុកនឹងបានសម្រេចដូចបំណងទៀតផង ។ បើជាអ្នកប្រកបមុខរបររកស៊ីវិញ គួរជួញដូរនៅទីជិតៗ ទើបសមប្រកប ។ រីឯបញ្ហាស្នេហាគូស្នេហ៍ចេះស្តាប់ឱវាទគ្នា ៕



# រូបមន្តមួយសប្តាហ៍អាចសម្រក ទម្ងន់បានកន្លះគីឡូក្រាម

**ស្ត្រីគ្រប់រូប គឺចង់បានរាងតូចច្រឡឹង ព្រោះស្លៀកអ្វីក៏សម ដូច្នេះ កុំបង្អង់យូរប្រញាប់អានឃ្លាបន្ត**

**-វិធីអនុវត្តមិនពិបាក :** ការផឹកទឹកតែលទ្ធផលដែលទទួលទាន គួរឱ្យពេញចិត្ត ព្រោះវាជួយឱ្យអ្នកស្រកទម្ងន់បានរហូតដល់កន្លះគីឡូក្រាមក្នុងមួយសប្តាហ៍ឯណោះ ។

**- ចៀសវាងអំបិល :** ក្នុងនោះរួមទាំងអាហាររសជាតិប្រៃទាំងឡាយ ព្រោះសូដ្យូមពីអំបិលនេះធ្វើឱ្យកោសិកាត្រូវកាត់ស្តុកជាតិទឹកច្រើនខុសពីធម្មតា ។ នេះជាហេតុផលរុញច្រានឱ្យរាងកាយទ្រលុកទ្រលន់ទៅដោយជាតិទឹក ប៉ុន្តែប្រសិនបើអ្នកទទួលទានសាបទម្ងន់ខ្លួននឹងស្រកចុះយ៉ាងរហ័ស ។

**-ទឹកផ្លែម្នាស់ :** ប្រសិនបើស្តមព្យាយាមក្រោកពីព្រលឹមបន្តិចរួចយកទឹកម្នាស់ស្រស់ៗទទួលទានមុនអាហារពេលព្រឹករាល់ថ្ងៃ ។ អង់ហ្ស៊ីម នៅក្នុងផ្លែម្នាស់ជួយបំបែកសារជាតិខ្លាញ់ និងកើនជាតិអាស៊ីដនៅក្នុងក្រពះ ។ អាហារដែលបានទទួលទានងាយនឹងរំលាយមិនកកផ្តុំនៅត្រង់ក្បាលពោះយូរ ។ បន្ទាប់មកកុំភ្លេចផឹកទឹកតាមក្រោយឱ្យបានច្រើនដើម្បីជួយសម្រួលដល់ប្រព័ន្ធបញ្ចេញចោល ។

**-បោះចោលរបស់ចាស់ :** សម្លៀកបំពាក់ចាស់ៗពិតមែនថា អ្នកមានអារម្មណ៏រលុងស្រួលមែន តែបើប្តូរមកស្លៀក សំលៀកបំពាក់ថ្មី រាងណែនវិញអាចធ្វើឱ្យអ្នកចាំបាច់ត្រូវកំណត់ការទទួលទានកាន់តែតិចទាំងព្រឹកថ្ងៃត្រង់ និងល្ងាចពិតជាធ្វើឱ្យអ្នកស្រកទម្ងន់បានយ៉ាងប្រាកដ ៕









# ខ្មែរអ្នកជាតិនិយម

**តពីលេខមុន**

កងទ័ពចិនទាំងអស់ត្រូវចេញពីតុងកឹង និងពីប្រទេសឡាវ ។ ឯបារាំងក៏ត្រូវប្រគល់ទៅប្រទេសចិនវិញ នូវសិទ្ធិខ្លះៗដែលខ្លួនធ្លាប់មាននៅឯសៀងហៃ្ស ជានទ្បិន្ទហាន់កែវ និងកង់តុង ព្រមទាំងប្រគល់ដីឈ្នួលក្វាងចេវវ៉ាន់ទៅឱ្យប្រទេសចិនវិញ ។ ឯកំពង់ផែហៃហ្វុង ក៏ឥតត្រូវយកពន្ធដាអាករលើផលិតផលចិន ហើយជនជាតិចិនដែលរស់នៅឥណ្ឌូចិនទាំងមូលនឹងត្រូវមានអភ័យឯកសិទ្ធិដូចជនជាតិបារាំង តាមលក្ខណៈផ្លូវច្បាប់ និងតុលាការដែរ ។

ថ្ងៃទី៦មីនា ១៩៤៦ នៅហាណូយ សាំងដឺនី (ខាងបារាំង) និង ហូ ជីមិញ( ខាងយួន) បានចុះហត្ថលេខាលើកិច្ចសន្យាមួយរវាងបារាំង និង យួនដែលចែងថា រដ្ឋាភិបាលបារាំងទទួលស្គាល់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមថា ជារដ្ឋសេរិ ដែលមានរដ្ឋាភិបាល រដ្ឋសភា យោធា និងហិរញ្ញវត្ថុផ្ទាល់ខ្លួន ហើយដែលនៅក្នុងសហព័ន្ធឥណ្ឌូចិន និងសហភាពបារាំង ។ ចំពោះការបង្រួបបង្រួមប្រទេសវៀតណាម, តុងកឹង្សអណ្ណាម និងកូសាំងស៊ិន បារាំងនឹងទទួលយល់ព្រមតាមសេចក្ដីសម្រេចចិត្តរបស់បណ្ដាជនតាមប្រជាមតិ ។ ឯពលទាហានបារាំងចំនួន១៥,000នាក់នឹងត្រូវចូលទៅតុងកឹងជំនួសកងទ័ពចិន ហើយក្នុងរយៈពេល៥ឆ្នាំក្រោយមកត្រូវដកចេញឱ្យអស់ពីប្រទេសវៀតណាម ។ លក្ខខណ្ឌនេះស្របនឹងគោលដៅរបស់ ហូ ជីមិញ ខ្លាំងណាស់ហើយគាត់យល់ព្រមមួយរយភាគរយឥតជជែកតវ៉ាឡើយ ។




ការដោះស្រាយខាងលើតាមគំនិតរបស់ឧត្ដមសេនីយ៍ ឡឺក្លែរ នេះ វាផ្ទុយស្រឡះពីគំនិត ជាសង់ឱយើរ ជាមនុស្សជំនិតរបស់ ដឺហ្គោល ដែលយល់ថាការយកឥណ្ឌូចិនមកវិញត្រូវធ្វើតាមកម្លាំងយោធាឯរបបគ្រប់គ្រងវិញ គឺជារបបអាណានិគមនិយមជំនាន់មុន ។ ការខ្វែងគំនិតគ្នានេះបានក្លាយទៅជាការប្រជែងគ្នារវាងបុគ្គលទាំងពីរយ៉ាងឆាប់រហ័សតែជាអកុសល បន្ទាប់មកឧត្ដមសេនីយ៍ ឡឺក្លែរ បានស្លាប់ក្នុងគ្រោះថ្នាក់យន្ដហោះមួយដែលអ្នកផងសង្ស័យថា មកពីការខ្វែងគំនិតនៃបុគ្គលទាំងពីរនាក់ ។ តមកទៀត ក្នុងការប្រយុទ្ធដ៏ស្វិតស្វាញរបស់ ហូ ជីមិញ ដើម្បីភ្ជាប់ទឹកដីកូសាំងស៊ីន ទៅជាមួយវៀតណាមនោះ ឧត្ដមនាវី ដាសង់ឌីយើរ បានលេងសន្លឹកបៀកូសាំងស៊ីនផ្សេងវៀតណាមផ្សឹង ។ សន្លឹកបៀរនេះហើយដែលជម្រុញប្រទេសបារាំងឱ្យបញ្ចេះសង្គ្រាមមួយដែលប្រវត្តិសាស្ត្រពិភពលោកឱ្យឈ្មោះថា សង្គ្រាមវៀតណាម ។

**ការកកើតខ្មែរឥស្សរៈ**

នៅប្រទេសកម្ពុជាបន្ទាប់ពីពេលដែលបារាំងចាប់លោក សឺន ង៉ុកថាន់ យកទៅដាក់គុកនៅព្រៃនគររួចនិរទេសទៅប្រទេសបារាំងនោះបណ្ដាជនខ្មែរភាគច្រើនយល់ថា ស្ដេច សីហនុ បានលើកប្រទេសជាតិខ្មែរទៅឱ្យបារាំងក្នុងកលល្បិចរក្សារាជសម្បត្តិរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ។ ឯក្រុមអ្នកជាតិនិយមវិញ បានវិនិច្ឆ័យថា កម្លាំងសឹក គឺជាមធ្យោបាយតែមួយគត់ក្នុងការតស៊ូច្បាំងយកឯករាជ្យពីបារាំងមកវិញ រួចក៏នាំគ្នារត់ចូលព្រៃ ខ្លះទៅទិសខាងជើងតាមជាយដែនខ្មែរ-សៀម ខ្លះទៀតរត់ទៅព្រំដែនខ្មែរ-យួន ដើម្បីបង្កើតចលនាតស៊ូមួយឈ្មោះថា ឥស្សរៈ តាមមធ្យោបាយដែលខ្លួនអាចធ្វើទៅកើតទីទៃៗពីគ្នា ព្រោះបាត់មេបាត់កើយអស់ហើយ ។

រឿងនេះ អ្នកនិពន្ធឈ្មោះ David steinderg បានបញ្ជាក់ថា នៅប៉ែកខាងជើងប្រទេសចលនាឥស្សរៈនេះ បានកើតមានឡើង តាំងតែពីសម័យក្រោយមហាបាតុកម្មឆ្នាំ១៩៤២ម្ល៉េះ គឺជាក្រុមអ្នកជាតិនិយម សឺន ង៉ុនថាន់ ដែលបានភៀសខ្លួនចូលទៅជ្រកកោននៅខេត្តបាត់ដំបង ដែលកាលនោះនៅក្រោមការត្រួតត្រារបស់ថៃបានរៀបចំចរលនាសម្ព័ន្ធនៃចលនាឥស្សរៈនេះ ដោយមានថៃជួយគាំទ្រផង។ កងឥស្សរៈនេះ បានវាយប្រហារកាន់កាប់ទីក្រុងសៀមរាបម្ដងនៅថ្ងៃទី៨ សីហា ១៩៤៦ នោះពួកឥស្សរៈទាំងនោះ ក៏បានចូលទៅនៅក្នុងក្រុងបាងកកគឺនៅទីនោះហើយដែលខ្មែរអ្នកជាតិនិយមដទៃទៀតបានមកដល់បន្តបន្ទាប់គ្នា ។

នៅខែកញ្ញា ឆ្នាំ១៩៤៧ ក្រុមអ្នកជាតិនិយមបានប្រកាសនូវការកកើតឡើងនៃរដ្ឋាភិបាលកម្ពុជាសេរីដែលរដ្ឋាភិបាលថៃរបស់ ព្រីឌី ភ្នំយោង បានទទួលស្គាល់ជាផ្លូវការផង ។ ប៉ុន្ដែលុះដល់ភិបុលសង្គ្រាមត្រឡប់មកកាន់អំណាចវិញ ពួកខ្មែរឥស្សរៈទាំងនោះ ត្រូវបានសៀមហាមឃាត់មិនឱ្យធ្វើសកម្មភាពនៅលើទឹកដីសៀមឡើយ ។

លុះត្រឡប់មករស់នៅក្នុងទឹកដីខ្មែរវិញ អ្នកដឹកនាំខ្មែរឥស្សរៈប្រមាណ១២នាក់ ក៏បានបង្កើតគណៈកម្មការរំដោះជាតិមួយនៅក្រោមការដឹកនាំរបស់ ដាប ឈួន ។ តែគណៈកម្មការនេះឥតមានប្រសិទ្ធភាពសោះ ព្រោះខ្វះមធ្យោបាយរួបរួមគ្នា

**តទៅលេខក្រោយ**



# តើអាហារអ្វីខ្លះជួយសុខភាពខួរក្បាល

ខួរក្បាលដើរតួនាទីយ៉ាងសំខាន់ក្នុងជីវិតប្រចាំថ្ងៃ ។ សុខភាពខួរក្បាលល្អ អាចឱ្យអ្នកគិតគ្រប់កិច្ចការបានរហ័ស និងមានគំនិតច្នៃប្រឌិតច្រើន ។ ដូច្នេះការថែរក្សាសុខភាពខួរក្បាលជារឿងដែលចាំបាច់ត្រូវយល់ដឹង ។ ខាងក្រោមនេះ គឺជាអាហារដែលល្អសម្រាប់ជួយសុខភាពខួរក្បាល ។



**-ទទួលទានត្រី :** ត្រីជាអាហារដ៏ល្អសម្រាប់ខួរក្បាល ព្រោះវាសម្បូរដោយជាតិប្រូតេអ៊ីន និងសារធាតុអាស៊ីដអូមេហ្គា៣ ។ ទន្ទឹមនឹងនេះ អ្នកក៏ត្រូវប្រុងប្រយ័ត្នក្នុងការជ្រើសរើសប្រភេទត្រីមកទទួលទានដែរ ។ ត្រូវជ្រើសរើសប្រភេទត្រីដែលមិនសូវមានជាតិបារត ព្រោះជាតិបារតប្រឆាំងនឹងជាតិអូមេហ្គាដ៏ល្អសម្រាប់រាងកាយ ។ ត្រីដែលល្អសម្រាប់ទទួលទានមានដូចជា ត្រីសូម៉ុង ត្រី អណ្តែង ត្រីអណ្តាតឆ្កែ និងត្រីរៀលជាដើម ។

**-ទទួលទានបន្លែ :** បន្លែពណ៌បៃតងមួយចំនួនដែលល្អចំពោះខួរក្បាលមាន ខាត់ណាខៀវ (Broccoli) ស្ពៃខៀវ ម្ទេស ផ្សិត ការ៉ុត និងស្ពៃក្តោប សុទ្ធតែជា បន្លែដែលល្អចំពោះខួរក្បាល ។

**-ទទួលទានផ្លែឈើ :** ផ្លែប៊ឺ សម្បូរទៅដោយ Monounsaturated Fats ដែលល្អចំពោះសុខភាពខួរក្បាល ។វិធីជ្រើសរើសផ្លែឈើ គឺត្រូវជ្រើសរើសផ្លែឈើណាដែលមានសម្បុរស្រស់ល្អ ។ ផ្លែប៊ែរីក៏ជាផ្លែឈើជួយជំរុញថាមពលខួរក្បាលដែរ ។

**- សូកូឡាខ្មៅ :** សូកូឡាសម្បូរទៅដោយជាតិ Flavonoids ។ ជាតិ Flavo- noids ជួយ សម្រួលដល់លំហូរឈាមទៅកាន់សរសៃឈាមខួរក្បាល ដូច្នេះវាអាចជួយបង្កើនសមត្ថភាពការគិតរបស់អ្នក ។ បើទោះបីជាសូកូឡាល្អសម្រាប់ខួរក្បាលក៏ដោយក៏ការទទួលទានសូកូឡា គួរធ្វើឡើងឱ្យបានសមស្របមិនច្រើន ហួសហេតុដែលនាំទៅរកបញ្ហាសុខភាពផ្សេងទៀត ។

**-សណ្តែកសៀង :** សណ្តែកសៀងផ្ទុកទៅដោយសារធាតុ Choline, Lecithin និង Isoflavones ដែលជួយជំរុញខួរក្បាល និងកាត់បន្ថយភាពភ្លេចភ្លាំង ៕






$150 REBATE
សងប្រាក់ $150មកវិញ
ចំពោះការទិញទូរស័ព្ទ"ស្មាត ហ្វូន"ដែលអ្នកបានជ្រើសយក
Towards the smart phone of your choice!
(terms and conditions apply)
Washington SAVINGS BANK
We give you more
Member FDIC / Member DIF
washingtonsavings.com
Free Gift: Customer will receive a free gift within 30 days after redeeming a "FREE GIFT Certificate", including a smart phone purchase receipt and newly activating the following combination of services after 08/15/2013: A monthly direct deposit of at least $1,000 from an unaffiliated third party that is income or government benefit based, at least one monthly automatic withdrawal/ payment that is not web or card based and repetitive in nature; and an active debit card with 12 or more completed purchases is eligible for a $150 rebate from a smart phone purchase from any vendor. Promotion ends 06/30/2014. Each depositor is insured by the FDIC to at least $250,000. All deposits above the FDIC insurance amount are insured by the Depositors Insurance Fund (DIF).
ចុះឈ្មោះតាមអ៊ិនធឺណិត
Make deposits with your mobile device anytime, anywhere
ឆិកឃីងអេកខានទាំងអស់ គឺមិនយកកំរៃ
All checking accounts are FREE
• No minimum balance (មិនចាំបាច់មានលុយតម្កល់ទាបបំផុត)
• No monthly service fees (មិនគិតថ្លៃសេវាប្រចាំខែ)
• Free designer debit card (ទទួលបានដេប៊ីតខាតឱសាញ្ញដោយឥតយកថ្លៃ)
• Free online banking, mobile banking (សេវាធនាគារតាមអ៊ិនធឺណិត និងទូរស័ព្ទចល័តឥតយកថ្លៃ
• Nationwide surcharge free or ATM refunds (មិនយកកំរៃបន្ថែមលើសេវាទូលំទូលាយ ឬសង ATM)
(depending on type of account)
ទទួលបានរង្វាន់រាល់ថ្ងៃពីសកម្មភាពដែលអ្នកប្រើពីធនាគារ
Also earn rewards for everyday banking activity!
(example: e-statements, payments and debit card use)
Debit Cash Rewards
រង្វាន់ជាប្រាក់សុទ្ធពីដេប៊ីតកាត
Tune Rewards
រង្វាន់ជាតន្ត្រី
Interest Rewards
រង្វាន់ជាការប្រាក់
Over 85 debit card designs!
washingtonsavings.com Member FDIC/Member DIF